ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ថវិកាសង្ខេប ឆ្នាំ ២០២៦

# BUDGET IN BRIEF

## Fiscal Year 2026

នាយកដ្ឋានថវិកានីយកម្ម

អគ្គនាយកដ្ឋានថវិកា



# មាតិកា

ទំព័រ

**ជំពូក ១. សេចក្តីផ្តើម** ២

១.១. បរិការណ៍រួមនៃការរៀបចំថវិកាឆ្នាំ ២០២៦ ២

១.២. បញ្ហាប្រឈម និង ហានិភ័យ ៣

១.៣. គោលការណ៍សំខាន់ៗនៃការរៀបចំថវិកាឆ្នាំ ២០២៦ ៤

**ជំពូក ២. ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០២៦** ៦

២.១. សូចនាករសេដ្ឋកិច្ច ៦

២.២. កំណើនតាមវិស័យសំខាន់ៗ ៧

**ជំពូក ៣. ក្របខ័ណ្ឌថវិកាឆ្នាំ ២០២៦** ១០

៣.១. ស្ថានភាពចំណូលថវិការដ្ឋ ១៣

៣.២. ស្ថានភាពចំណាយថវិការដ្ឋ ១៤

៣.៣. ចំណាយថវិកាថ្នាក់ជាតិ ១៥

៣.៤. ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ៣០

៣.៥. ការកំណត់ពិតាននៃការខ្ចីសម្រាប់ឆ្នាំ ២០២៦ ៣២

៣.៦. ស្ថានភាពបំណុល ៣៤

**ជំពូក ៤. សេចក្តីសន្និដ្ឋាន** ៣៧

**ជំពូក ៥ . តារាងឧបសម្ព័ន្ធ** ៣៩

៥.១. ថវិកាកម្មវិធីរបស់ក្រសួង-ស្ថាប័ន តាមកម្មវិធី អនុកម្មវិធី ៣៩

៥.២. ចំណាយថវិកាសរុបរបស់ក្រសួង-ស្ថាប័ន ៧១

# ជំពូក ១. សេចក្ដីផ្ដើម

## ១.១. បរិការណ៍រួមនៃការរៀបចំថវិកាឆ្នាំ ២០២៦

ច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៦ ត្រូវបានរៀបចំឡើងក្នុងបរិការណ៍ដែលរាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា កំពុងបន្តជំរុញអនុវត្តយ៉ាងសស្រាក់សស្រាំនូវបេសកកម្មដ៏ឧត្ដុង្គឧត្ដមជាប្រវត្តិសាស្ត្ររបស់ខ្លួន ជាមួយនឹងការប្ដេជ្ញាចិត្តយ៉ាងមុតមាំឥតរាថយក្នុងការការពារអធិបតេយ្យជាតិ បូរណភាពទឹកដី និង ថែរក្សាសុខសន្តិភាព ជូនប្រជាជន ក៏ដូចជាក្នុងការពន្លឿនកិច្ចអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងកិច្ចការកែទម្រង់កាន់តែស៊ីជម្រៅលើគ្រប់វិស័យលើមាគ៌ា បន្តឈានទៅសម្រេចឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ នាពេលខាងមុខ។ ឈរលើមូលដ្ឋាននេះ ច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៦ មានគោលដៅពង្រឹងសមត្ថភាពការពារអធិបតេយ្យជាតិ និង បូរណភាពទឹកដី និងបន្តគាំទ្រការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេសការអនុវត្តអាទិភាពគោលនយោបាយសំខាន់ៗ និងវិធានការគន្លឹះនានា ដែលត្រូវបានដាក់ឱ្យអនុវត្តជាបន្តបន្ទាប់ ចាប់ពីដើមនីតិកាលទី ៧ នៃរដ្ឋសភា ឱ្យសម្រេចបាននូវលទ្ធផលផ្លែផ្កាជាអតិបរមា ដើម្បីឆ្លើយតបទៅនឹងសំណូមពរ សេចក្ដីត្រូវការ ការរំពឹងទុក និងក្ដីប្រាថ្នារបស់ប្រជាជនកម្ពុជាដែលជាម្ចាស់ឆ្នោត។ ទន្ទឹមនេះ, ក្នុងបរិការណ៍នៃការទទួលរងនូវការឈ្លានពាន និងការបន្តរំលោភបំពានជាបន្តបន្ទាប់មកលើអធិបតេយ្យជាតិ និងបូរណភាពទឹកដី នៅតាមបណ្ដោយព្រំដែនកម្ពុជា-ថៃ កម្ពុជាក៏នៅបន្តជួបប្រឈមនឹងហានិភ័យ និងភាពមិនប្រាកដប្រជាខ្ពស់ពីកត្តាខាងក្រៅ ដែលជាប្រការអាចយាយីដល់កិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការបន្តអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច សម្រាប់រយៈពេលខ្លី និងមធ្យមខាងមុខ។

ដូចនេះ, ថវិកាឆ្នាំ ២០២៦ ត្រូវបានគិតគូរ និងរៀបចំឡើងដោយផ្ដោតលើអាទិភាពសំខាន់ៗ បំផុតចំពោះមុខ, ជាពិសេស ការពង្រឹងសមត្ថភាពការពារអធិបតេយ្យជាតិ និង បូរណភាពទឹកដី, ការរក្សាលំនឹងសង្គម-សេដ្ឋកិច្ច និង ជីវភាពប្រជាជន, ការលើកកម្ពស់សមធម៌សង្គម, ការបន្តទ្រទ្រង់ដំណើរការនៃកិច្ចអភិវឌ្ឍសង្គម, ការបន្តគាំទ្រការទ្រទ្រង់និរន្តរភាពនៃប្រតិបត្តិការរបស់ស្ថាប័នរដ្ឋ ព្រមទាំងជំរុញការអនុវត្តអាទិភាពគោល-នយោបាយសំខាន់ៗ និង វិធានការកែទម្រង់គន្លឹះដាក់លាក់នានា ដែលត្រូវបន្តអនុវត្តក្នុងឆ្នាំ ២០២៦, ជាពិសេស ការបន្តជំរុញអនុវត្តកម្មវិធីគោលនយោបាយអាទិភាពទាំង ៦ និង

វិធានការគន្លឹះទាំង ៥ ដែលរាជរដ្ឋាភិបាលបានដាក់ចេញ សំដៅដោះស្រាយបញ្ហាប្រឈមជាអាទិភាព និងសម្រេចឱ្យបានជាអតិបរមានូវគោលដៅជាយុទ្ធសាស្ត្រទាំង ៥ ដូចមានចែងក្នុង **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** ដើម្បីឆ្លើយតបទៅនឹងទិសដៅនៃការអភិវឌ្ឍរបស់កម្ពុជា ក្នុងដំណាក់កាលថ្មី, ទាំងក្នុងក្របខ័ណ្ឌផ្ទៃក្នុងប្រទេស, ក៏ដូចជាក្នុងក្របខ័ណ្ឌតំបន់ និង ពិភពលោកផងដែរ។

## ១.២. បញ្ហាប្រឈម និង ហានិភ័យ

សម្រាប់ឆ្នាំ ២០២៦ សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករថា នឹងសម្រេចបានកំណើនក្នុងរង្វង់ **៥,០%** ក្នុងបរិការណ៍នៃការកើនឡើងនូវបញ្ហាប្រឈម និងហានិភ័យពីកត្តាខាងក្រៅ និងកត្តាខាងក្នុង ដែលបាននិងកំពុងបង្កការគំរាមមកលើចីរភាព និងនិរន្តរភាពនៃការអភិវឌ្ឍកម្ពុជា ដែលក្នុងនោះ៖

**កត្តាខាងក្រៅ មានជាអាទិ៍ ៖**

១)-កំណើនថមថយនៃសេដ្ឋកិច្ចសកល;

២)-ភាពតានតឹងនៃកត្តាភូមិសាស្ត្រនយោបាយដោយសារការអូសបន្លាយនៃសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន និងសង្គ្រាមរវាងអ៊ីស្រាអែល និងក្រុមហាម៉ាសជាដើម;

៣)-កម្មវិបាកនៃការបន្តកើនឡើងនៃចរន្តគាំពារនិយម ការបែកខ្ញែកភូមិសាស្ត្រសេដ្ឋកិច្ចដែលបន្ទច់បង្អាក់ដល់ប្រវាក់ផ្គត់ផ្គង់សកល និងមានការហក់ឡើងវិញនៃថ្លៃទំនិញសកល;

៤)-ការបន្តកើនឡើងសម្ពាធបំណុលសាធារណៈរបស់ពិភពលោក; និង

៥)-ផលប៉ះពាល់កាន់តែធ្ងន់ធ្ងរពីការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ។

**កត្តាខាងក្នុង មានជាអាទិ៍ ៖**

១)-ថ្លៃដើមធ្វើធុរកិច្ចនៅមានកម្រិតខ្ពស់ធៀបនឹងប្រទេសផ្សេងក្នុងតំបន់;

២)-ភាពមានកម្រិតនៃកិច្ចសម្រួលពាណិជ្ជកម្មនិងបរិយាកាសធុរកិច្ច;

៣)-ភាពមានកម្រិតនៃកម្លាំងពលកម្មជំនាញ ទាំងបរិមាណ និង គុណភាព ដែលមិនទាន់អាចឆ្លើយតបទៅនឹងតម្រូវការទីផ្សារ;

៤)-ភាពមានកម្រិតនៃប្រព័ន្ធសុខាភិបាលនិងប្រព័ន្ធគាំពារសង្គម; និង

៥)-ភាពមានកម្រិតនៃចំណេះដឹង និងជំនាញក្នុងការចាប់យកបច្ចេកវិទ្យាឌីជីថល។

## ១.៣. គោលការណ៍សំខាន់ៗនៃការរៀបចំច្បាប់ថវិកាឆ្នាំ ២០២៦

ថវិកាឆ្នាំ ២០២៦ ត្រូវបានរៀបចំឡើងដោយឈរលើ**គោលការណ៍** និង**អភិក្រម** ដូចខាងក្រោម៖

**ទី១-ការគោរពឱ្យបាននូវក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចដែលបានកំណត់** ៖ ដើម្បីសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ដែលជាមូលដ្ឋានមិនអាចខ្វះបាន ដើម្បីបង្កើតការងារថ្មីកាន់តែច្រើនជូនប្រជាជន ជាពិសេសសម្រាប់ស្រទាប់យុវជន និងពលករវិលត្រឡប់ពីប្រទេសថៃ ដើម្បីផ្តល់លទ្ធភាពកាន់តែច្រើនឱ្យប្រជាជនទទួលបានប្រាក់ចំណូលកើនឡើងកាន់តែខ្ពស់ ក៏ដូចជាដើម្បីបង្កើនចំណូលថវិកាជាតិផងដែរ។

**ទី២-ការរក្សាតុល្យភាព និងចីរភាពថវិកា** ៖ គ្រោងថវិកាផ្អែកចំណាយផ្អែកលើលទ្ធភាពចំណូល ដែលមានប្រភពពីការប្រមូលចំណូលក្នុងប្រទេស ដោយមិនប្រើប្រាក់សន្សំរបស់រាជរដ្ឋាភិបាល ទន្ទឹមនេះ បង្កើនការកៀរគរហិរញ្ញប្បទានពីក្នុង និងក្រៅប្រទេស ដោយប្រកាន់ខ្ជាប់នូវគោលការណ៍គន្លឹះទាំង ៥ ដែលបានកំណត់ក្នុង **យុទ្ធសាស្រ្តស្តីពីការគ្រប់គ្រងបំណុលសាធារណៈ**។

**ទី៣-ការធានាចីរភាព និងសមិទ្ធកម្មនៃចំណូល** ៖ ដើម្បីសម្រេចបាននូវគោលដៅនៃការប្រមូលចំណូលតាមការកំណត់ ក៏ដូចជាដើម្បីឆ្លើយតបនឹងតម្រូវការចំណាយថវិកាជាតិនៅក្នុងឆ្នាំ ២០២៦ ក្រសួង ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាលដែលទទួលបន្ទុកកៀរគរចំណូលមិនមែនសារពើពន្ធ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលទទួលបន្ទុកកៀរគរចំណូលសារពើពន្ធ ចាំបាច់ត្រូវបន្តរក្សាចលនការនៃការខិតខំប្រឹងប្រែងក្នុងការកៀរគរចំណូលថវិកាឱ្យអស់សក្តានុពល ទន្ទឹមនឹងការបន្តរក្សានូវភាពប្រយ័ត្នប្រយែងដោយមិនបង្កផលប៉ះពាល់ដល់ការរស់នៅរបស់ប្រជាជន ការធ្វើធុរកិច្ច ប៉ុន្តែបង្កើនការពង្រឹងអភិបាលកិច្ច និងភាពយុត្តិធម៌ ក្នុងការផ្តល់សេវា និងការប្រមូលពន្ធដារ។

**ទី៤-ការតម្កល់មនុស្ស ជាអាទិភាពទី ១ ដោយផ្តោតលើ** ៖ (១)-ការរក្សាលំនឹងជីវភាពរស់នៅរបស់មន្ត្រីរាជការគ្រប់ថ្នាក់ (២)-ការពង្រឹងគុណភាព ប្រសិទ្ធភាព និងសមិទ្ធកម្មរបស់មន្ត្រី និងស្ថាប័ន ដោយបន្តពង្រឹងនិងពង្រីកការអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម ជាពិសេសផ្តល់ការលើកទឹកចិត្តចំពោះមន្ត្រីដែលមានគុណវុឌ្ឍិសំដៅបង្កើនផលិតភាពការងារ និងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃសេវាសាធារណៈ (៣)-ការលើកកម្ពស់គុណភាពអប់រំ និងគុណភាពសេវាសុខាភិបាល តាមរយៈការដាក់ឱ្យអនុវត្តនូវវិធានការគន្លឹះជាក់ស្តែងនានា សំដៅកសាងភាពធន់រឹងមាំប្រកបដោយចីរភាពនៃវិស័យមូលធនមនុស្ស និងសង្គម (៤)-ការរក្សាលំនឹងជីវភាពជូននិវត្តជន

និងជនបាត់បង់សម្បទាវិជ្ជាជីវៈជាអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន និង (៥)-ការពង្រឹង និងការលើកកម្ពស់ប្រសិទ្ធភាពការអនុវត្តគោលនយោបាយគាំពារសង្គម សំដៅលើកកម្ពស់សមធម៌ និងស្ថិរភាពសង្គម។

**ទី៥-ការធ្វើវិចារណកម្មលំដាប់អាទិភាពតាមរយៈ** : (១)-ការផ្តល់អាទិភាពដល់ការពង្រឹងសមត្ថភាពការពារអធិបតេយ្យជាតិ និងបូរណភាពទឹកដី, ការជានាប្រក្រតីភាព និងនិរន្តរភាពនៃដំណើរការក្រសួង ស្ថាប័ន, (២)-ការគាំទ្រដល់ការបន្តអនុវត្តគោលនយោបាយអាទិភាព និងវិធានការគន្លឹះសម្រាប់ដោះស្រាយបញ្ហាប្រឈមជាអាទិភាពក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, (៣)-ការទ្រទ្រង់ការងើបវិញ និងការជំរុញសកម្មភាពសេដ្ឋកិច្ច, (៤)-ការបន្តគាំទ្រ ឬបន្ថែមការគាំទ្រដល់កម្មវិធី/សកម្មភាពចាំបាច់ខ្លាំងដែលមិនខ្វះបាន ឬមិនអាចពន្យារពេលអនុវត្ត រួមមាន៖ (១)-តម្រង់ការបែងចែកថវិកាឱ្យបានត្រឹមត្រូវ និងចំគោលដៅ ដោយមិនផ្តល់ថវិកាសម្រាប់មុខចំណាយមិនចាំបាច់ និងចំណាយលែងចាំបាច់ (២)-រឹតបន្តឹងខ្លាំងក្នុងការផ្តល់ថវិកាសម្រាប់មុខចំណាយមិនសូវចាំបាច់ (៣)-បន្តផ្តល់ថវិកាចំពោះមុខចំណាយដែលចាំបាច់សម្រាប់ការអនុវត្តសកម្មភាពអាទិភាព និង (៤)-ហ៊ានចាយបន្ថែមលើមុខចំណាយដែលចាំបាច់ខ្លាំង។

**ទី៦-ការលើកកម្ពស់ប្រសិទ្ធភាពកម្មវិធី និង/ឬសកម្មភាព** : ដោយបន្តគិតគូរឱ្យកាន់តែហ្មត់ចត់លើភាពសមស្របនៃថ្លៃ បរិមាណ និងគុណភាព ព្រមទាំងជម្រើសបច្ចេកទេស ក្នុងការអនុវត្តកម្មវិធី និង/ឬសកម្មភាព ក្នុងគោលដៅបន្តលើកកម្ពស់បន្ថែមនូវប្រសិទ្ធភាពនៃការវិភាជថវិកា ក៏ដូចជាបង្កើនគុណភាពនៃការកំណត់សូចនាករគន្លឹះឱ្យបានសមស្រប។

**ទី៧-ការផ្ទេរថវិកាឱ្យដល់អង្គភាពអនុវត្ត** : ជំរុញ និងលើកទឹកចិត្តឱ្យក្រសួង ស្ថាប័នប្រែក្លាយអង្គភាពថវិកាក្រោមឱវាទ ឱ្យទៅជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ ដើម្បីអង្គភាពនីមួយៗមានកញ្ចប់ថវិកាផ្ទាល់ និងមានគណនេយ្យភាពចំពោះសមិទ្ធកម្មរបស់អង្គភាពខ្លួន។

**ទី៨-ការផ្សារភ្ជាប់រវាងការប្រមូលចំណូល និងការវិភាជថវិកា** : អនុវត្តការផ្សារភ្ជាប់ការវិភាជថវិកាទៅនឹងលទ្ធផលនៃការអនុវត្តចំណូល ដោយផ្តល់អាទិភាពលើចំណាយមិនមែនបុគ្គលិកសម្រាប់ក្រសួង ស្ថាប័នដែលខិតខំចំណូលប្រមូលចំណូលដោយផ្ទាល់។ ទន្ទឹមនេះ ក៏លើកទឹកចិត្តឱ្យក្រសួង ស្ថាប័នដែលទទួលបានរង្វាន់ពីការផ្តល់សេវាសាធារណៈប្រើប្រាស់ប្រាក់រង្វាន់ប្រកបដោយតម្លាភាព ដោយបែងចែកប្រាក់រង្វាន់ក្នុងទំហំសមស្របសម្រាប់ការអភិវឌ្ឍសមត្ថភាពស្ថាប័ន។

## ជំពូក ២. ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០២៦

### ២.១. សូចនាករសេដ្ឋកិច្ច

ផ្អែកតាមក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម និងយោងតាមការវាយតម្លៃឡើងវិញ សម្រាប់រយៈពេល ៩ ខែក្នុងឆ្នាំ ២០២៥, ស្ថានភាពសេដ្ឋកិច្ចកម្ពុជា អាចនឹងសម្រេចបានកំណើន **ក្នុងរង្វង់ ៥,២% សម្រាប់ឆ្នាំ ២០២៥ និង ៥% សម្រាប់ឆ្នាំ ២០២៦។** តាមលទ្ធផលនៃការព្យាករកំណើននេះ, ផ.ស.ស. ថ្លៃបច្ចុប្បន្ន ឆ្នាំ ២០២៦ ស្ថិតក្នុងរង្វង់ **២១៧ ០៦៣** ប៊ីលានរៀល, សមមូលនឹងប្រមាណ **៥៣ ៧៩៥** លានដុល្លារអាម៉េរិក ក្នុងខណៈដែល ផ.ស.ស. សម្រាប់មនុស្សម្នាក់ ត្រូវបានរំពឹងថានឹងកើនដល់ **៣ ០២០ ដុល្លារអាម៉េរិក។** ចំណែកឯ **អត្រាប្តូរប្រាក់រៀល** គឺនៅតែបន្តស្ថិតនៅក្នុងរង្វង់ **៤ ០៣៥ រៀល** ក្នុងមួយដុល្លារអាម៉េរិក ក្នុងឆ្នាំ ២០២៦។ **ឱនភាពគណនីចរន្ត (រួមបញ្ចូលបង្វែរ)** ត្រូវបានព្យាករថានឹងស្ថិតក្នុងរង្វង់ -៣,១% នៃ ផ.ស.ស ដោយសារ ការរំពឹងទុកនៃការបន្តរក្សាបាននូវសមតុល្យពាណិជ្ជកម្មស្របពេលចំណូលពីវិស័យទេសចរណ៍ត្រូវបានរំពឹងថានឹងមាននិន្នាការកើនឡើងត្រលប់មកវិញ។ **អត្រាអតិផរណាជាមធ្យមប្រចាំឆ្នាំ ត្រូវបានព្យាករថានឹងស្ថិតក្នុងរង្វង់ ២,៨% ក្នុងឆ្នាំ ២០២៦** ក្រោមការរំពឹងទុកថា ថ្លៃទំនិញអន្តរជាតិបន្តរក្សាបានស្ថិរភាព ជាពិសេសថ្លៃប្រេងឥន្ធនៈ ស្របពេលដែលការប្រើប្រាស់ក្នុងស្រុក និងសកម្មភាពចាយវាយនៅបន្តមាននិន្នាការវិជ្ជមាន។ **ទុនបម្រុងអន្តរជាតិសរុប** ត្រូវបានរំពឹងថានឹងបន្តកើនឡើងដល់ ២៧ ៩៨៩ លានដុល្លារអាម៉េរិក ក្នុងឆ្នាំ ២០២៦ និងធានាការនាំចូលបាន ៧,៩ ខែ។

| សូចនាករសេដ្ឋកិច្ច | ២០២៤<br>ប៉ាន់ស្មាន | ២០២៥<br>ប៉ាន់ស្មាន | ២០២៦<br>ព្យាករ |
|---|---|---|---|
| ផ.ស.ស. ថ្លៃបច្ចុប្បន្ន (ប៊ីលានរៀល) | ១៨៨ ៧៦៦ | ២០២ ២២០ | ២១៧ ០៦៣ |
| កំណើន ផ.ស.ស. ពិត (%) | ៦,០ | ៥,២ | ៥,០ |
| ផ.ស.ស. សម្រាប់មនុស្សម្នាក់ (ដុល្លារអាម៉េរិក) | ២ ៦៧៥ | ២ ៨៥៨ | ៣ ០២០ |
| អត្រាអតិផរណា (កំណើនជាមធ្យមប្រចាំឆ្នាំ) | ០,៨ | ២,៥ | ២,៨ |
| អត្រាប្តូរប្រាក់ (រៀល/ដុល្លារអាម៉េរិក) | ៤ ០៧០ | ៤ ០២៥ | ៤ ០៣៥ |
| សមតុល្យគណនីចរន្ត (រួមបញ្ចូលបង្វែរ) (%នៃ ផ.ស.ស.) | ០,៥ | -២,២ | -៣,១ |
| ទុនបម្រុងអន្តរជាតិ (លានដុល្លារអាម៉េរិក) | ២២ ៥១១ | ២៥ ០៥១ | ២៧ ៩៨៩ |
| ទុនបម្រុងអន្តរជាតិ (ចំនួនខែនៃការនាំចូល) | ៩,៦ | ៧,៨ | ៧,៩ |

*ប្រភព៖ ក្រសួងផែនការ និងធនាគារជាតិនៃកម្ពុជា សម្រាប់ឆ្នាំ ២០២៤ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ការប៉ាន់ស្មានឆ្នាំ ២០២៥ និងការព្យាករឆ្នាំ ២០២៦ នៅក្នុងខែ កញ្ញា ឆ្នាំ ២០២៥*

## ២.២. កំណើនតាមវិស័យសំខាន់ៗ




តាមការព្យាករណ៍ កំណើនសេដ្ឋកិច្ចកម្ពុជានៅក្នុងឆ្នាំ ២០២៦ ត្រូវបានទ្រទ្រង់ដោយ៖



(ទី១)- **វិស័យឧស្សាហកម្ម** ត្រូវបានព្យាករថានឹងមានកំណើនក្នុងរង្វង់ **៧,២% ក្នុងឆ្នាំ ២០២៦** ដែលជាកំណើនថមថយ បើធៀបនឹងកំណើនឆ្នាំ ២០២៥ ដោយសារការថមថយចលនការនៃកំណើនវិស័យបម្រើការនាំចេញពេលគឺ អនុវិស័យកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ ក្រោមការរំពឹងទុក បច្ច័យនៃការអនុវត្តពន្ធគយបដិការ ដែលនឹងធ្វើឱ្យតម្រូវការសកលមាននិន្នាការថមថយ, ប៉ុន្តែជារួម នៅតែជាកំណើនល្អដោយសាររោងចក្រ-សហគ្រាស មានលទ្ធភាពបន្សាំខ្លួនបានបន្តិចម្តងៗទៅនឹងរបត់គោលនយោបាយពាណិជ្ជកម្ម និងសមតាពាណិជ្ជកម្មថ្មីនេះ។ **អនុវិស័យកាត់ដេរ** ត្រូវបានព្យាករថានឹងបន្តរក្សាបាននូវចលនការកំណើន ត្បិតការនាំចេញទៅទីផ្សារសហរដ្ឋ-អាម៉េរិក អាចប្រឈមនឹងហានិភ័យនៃការថមថយតម្រូវការ; ប៉ុន្តែ, នៅបន្តគាំទ្រដោយនិន្នាការវិជ្ជមាននៃការធ្វើពិពិធកម្មទីផ្សារនាំចេញរបស់កម្ពុជា (ផ្នែកតម្រូវការ) មួយចំនួនដូចជា សហភាពអឺរ៉ុប និង អាស៊ាន ជាដើម គួបផ្សំនឹងការពង្រឹងការអនុវត្ត «**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា ២០២២-២០២៧**» ដែលនឹងលើកកម្ពស់បរិយាកាសវិនិយោគ និងបង្កើនភាពប្រកួតប្រជែង (ផ្នែកផ្គត់ផ្គង់) ក៏ដូចជាចូលរួមបង្កើនតម្លៃបន្ថែមក្នុងអនុវិស័យនេះជារួម។ ជាមួយគ្នានេះ, **អនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ** ត្រូវបានព្យាករថានឹងមានកំណើនងើបមកវិញក្នុងឆ្នាំ ២០២៦ ប៉ុន្តែក្នុង

ល្បឿនទាប ដោយម៉្យាង, មានការជំរុញការនាំចេញផលិតផលឧស្សាហកម្មយុទ្ធសាស្ត្រសំខាន់ៗក្រោមរបត់គោលនយោបាយពាណិជ្ជកម្មថ្មី និងម៉្យាងទៀត, ឧស្សាហកម្មបម្រើទីផ្សារក្នុងស្រុក ក៏បន្តទទួលរងនូវកម្មវិបាកដោយសារការបិទខ្ទប់ច្រកព្រំដែនគោកកម្ពុជា-ថៃ ដែលការណ៍នេះអាចបន្ទច់បង្អាក់ដល់សមត្ថភាព និងសក្តានុពលផលិតកម្មរបស់រោងចក្រ-សហគ្រាសមួយចំនួន។ ស្របគ្នានេះ, **អនុវិស័យផលិតកម្មម្ហូបអាហារ និងអនុវិស័យភេសជ្ជៈនិងថ្នាំជក់** រំពឹងថានឹងបន្តនិន្នាការកើនឡើង ដែលជំរុញដោយការបន្តបង្កើនសកម្មភាពវិនិយោគ និងផលិតកម្ម។ ទោះជាយ៉ាងនេះក្តី, **អនុវិស័យសំណង់** ត្រូវបានព្យាករថានឹងបន្តងើប ក៏ប៉ុន្តែក្នុងសភាពយឺត ហើយនៅមានកំណើនទាបជាងនិន្នាការមុនវិបត្តិជំងឺកូវីដ-១៩ ដែលបន្តទ្រទ្រង់ដោយសកម្មភាពសាងសង់លំនៅឋាន ឆ្លើយតបទៅនឹងតម្រូវការពិតក្នុងស្រុក គួបផ្សំនឹងការបន្តនិន្នាការកើនឡើងនៃសកម្មភាពសំណង់បម្រើឱ្យវិស័យឧស្សាហកម្មមួយចំនួនដូចជា រោងចក្រ និងឃ្លាំងជាដើម ដែលនឹងក្លាយជានិន្នាការថ្មីជួយគាំពារកំណើននៃអនុវិស័យនេះ ក្នុងរយៈពេលខ្លី និងមធ្យមខាងមុខ។



(ទី២)- **វិស័យសេវាកម្ម** ត្រូវបានព្យាករថានឹងមានកំណើនទាបក្នុងរង្វង់ **៣,៧% ក្នុងឆ្នាំ ២០២៦** ដោយសារការរំពឹងទុកនៃការអូសបន្លាយផលប៉ះពាល់ពីការបិទខ្ទប់ព្រំដែនគោកកម្ពុជា-ថៃ មកលើចលនការនៃអនុវិស័យចន្ទល់កំណើនសំខាន់ៗមួយចំនួន ដូចជា អនុវិស័យបដិសណ្ឋារកិច្ច និងសេវាកម្មម្ហូបអាហារ (ទេសចរណ៍) លក់ដុំ-រាយ និងហិរញ្ញវត្ថុ និងជានាវ៉ាប់រង។ **អនុវិស័យបដិសណ្ឋារកិច្ច និងសេវាកម្មម្ហូបអាហារ** ត្រូវបានព្យាករថានឹងងើបឡើងវិញសន្សឹមៗ ផ្អែកលើការរំពឹងទុកការងើបឡើងវិញនៃភ្ញៀវទេសចរអន្តរជាតិបន្ទាប់ពីទទួលរងផលប៉ះពាល់គួរឱ្យកត់សម្គាល់ក្នុងឆ្នាំ ២០២៥ ដោយសារការបិទខ្ទប់ព្រំដែនគោកកម្ពុជា-ថៃ។ គួរបញ្ជាក់ថា បើទោះបីស្ថានភាពនៃវិស័យទេសចរណ៍ ជាពិសេសទេសចរណ៍ដែលពឹងផ្អែកលើទីផ្សារ និងកញ្ចប់ទេសចរណ៍ថៃ ត្រូវបានរំពឹងថានឹងមិនអាចវិលត្រលប់ទៅរកប្រក្រតីភាព ក៏និន្នាការទេសចរណ៍ទីផ្សារផ្សេងទៀត ដូចជា: ការដាក់ឱ្យដំណើរការនៃ **អាកាសយានដ្ឋានអន្តរជាតិតេជោ** ដែលនឹងក្លាយជាច្រកទ្វារអន្តរជាតិថ្មីមួយ ដ៏សំខាន់ក្នុងការទាក់ទាញភ្ញៀវទេសចរផ្លូវឆ្ងាយ និងការបំផុសឱ្យមានដំណើរកំសាន្តក្នុង**រដូវកាលបៃតង** (Green Season) របស់ក្រសួងទេសចរណ៍ដើម្បីជំរុញដោយការកើនឡើង នៃនិន្នាការធ្វើដំណើរកំសាន្តក្នុងស្រុក។

**អនុវិស័យអចលនទ្រព្យ** ដូចគ្នាទៅនឹងអនុវិស័យសំណង់ ក៏ងើបវិញយឺត ដែលបន្តគាំទ្រដោយចរន្តទិញ-លក់លំនៅឋានថ្លៃសមរម្យ សកម្មភាពទិញ-លក់/ជួលឃ្លាំង និងរោងចក្របម្រើឱ្យវិស័យឧស្សាហកម្ម។ **អនុវិស័យលក់ដុំ-រាយ** ត្រូវបានព្យាករថានឹងមានកំណើនថមថយក្នុងឆ្នាំ ២០២៦ ដោយសារការរំពឹងទុកការស្រកស្រុតនៃកម្លាំងទិញរបស់ប្រជាជនជារួម ដែលមួយផ្នែក គឺជាកម្មវិបាកនៃការបិទខ្ទប់ព្រំដែនកម្ពុជា-ថៃ ដែលជំរុញឱ្យមានការវិលត្រលប់មកវិញយ៉ាងគំហុកនៃពលករកម្ពុជាពីប្រទេសថៃ និងផលប៉ះពាល់លើការងារ និងស្ថិរភាពចំណូល។ **អនុវិស័យដឹកជញ្ជូន និងស្តុក** ទោះបីមានកំណើនថមថយបន្តិចក្នុងឆ្នាំ ២០២៦ ក៏កំណើនក្នុងរយៈពេលមធ្យមខាងមុខ នៅបន្តរក្សាបាននិន្នាការកើនឡើងដោយសារការបន្តងើបវិញនៃអនុវិស័យគាំទ្រមួយចំនួន ដូចជា អនុវិស័យកាត់ដេរ និងមិនមែនកាត់ដេរ គួបផ្សំនឹងការបន្តកើនឡើងនៃការដឹកជញ្ជូនបញ្ញើរហ័សក្នុងស្រុក។ ជាមួយគ្នានេះ, ការបន្តវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ទាំងផ្លូវអាកាស, ផ្លូវទឹក (កំពង់ផែ) និងផ្លូវគោក ក៏នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញ និងការគាំពារកំណើននៃអនុវិស័យនេះ។ **អនុវិស័យហិរញ្ញវត្ថុ និងធានារ៉ាប់រង** នៅបន្តធ្វើទំនើបកម្ម និងសាមញ្ញកម្មនៃប្រព័ន្ធហិរញ្ញវត្ថុ ជាពិសេស ផលិតផល និងសេវាហិរញ្ញវត្ថុ ស្របតាម «គោលនយោបាយអភិវឌ្ឍន៍បច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨» នឹងចូលរួមបង្កើនតម្លៃបន្ថែមទៀតដល់អនុវិស័យនេះផងដែរក្នុងរយៈពេលខ្លី និងមធ្យមខាងមុខ។ **អនុវិស័យបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍** ត្រូវបានព្យាករថា បន្តកើនប្រហាក់ប្រហែលទៅនឹងនិន្នាការនៃប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយសារការបន្តកើនឡើងនៃការប្រើប្រាស់អ៊ីនធឺណិត និងការបន្តធ្វើឌីជីថលូបនីយកម្មនៃផលិតផល និងសេវាកម្មក្នុងគ្រប់វិស័យ និងប្រភេទអាជីវកម្ម ជាមួយនឹងការបន្តពង្រឹងការអនុវត្តក្របខ័ណ្ឌគោលនយោបាយ មានជាអាទិ៍ «គោលនយោបាយអភិវឌ្ឍន៍បច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨», «គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥» និង «ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥» ជាដើម។



**(ទី៣)-វិស័យកសិកម្ម** ត្រូវបានព្យាករថាកើនឡើង **0,៩% ក្នុងឆ្នាំ ២០២៦** ដែលបន្តគាំទ្រដោយអនុវិស័យនេសាទ និងចិញ្ចឹមសត្វ ក្នុងខណៈដែលអនុ-វិស័យដំណាំអាចនឹងមានកំណើនយឺតជាងការរំពឹងទុកបន្តិច ដោយសារ

បច្ច័យនៃការធ្លាក់ចុះកសិផលមកលើស្ថានភាពផលិតកម្មក្នុងឆ្នាំ ២០២៦។ អនុវិស័យដំណាំ ត្រូវបានរំពឹងថាអាចមានកំណើនថមថយបន្តិច ដោយសារកម្មវិបាកនៃការធ្លាក់ចុះថ្លៃកសិផលក្នុងឆ្នាំ ២០២៥ មកលើកម្លាំងផលិតកម្ម ក្នុងឆ្នាំ ២០២៦ ជាពិសេសលើមុខទំនិញសំខាន់ៗ ដូចជា ស្រូវ ពោត និងដំឡូងមី ជាដើម។ ប៉ុន្តែ, ជារួម អនុវិស័យនេះក៏នៅតែរក្សាបានកំណើនវិជ្ជមាន ដែលបន្តគាំទ្រដោយការបន្តលើកកម្ពស់ការវិនិយោគទាំងក្នុងស្រុក និងពីបរទេសលើការកែច្នៃផលិតផលកសិកម្ម។ ទន្ទឹមនេះ, អនុវិស័យចិញ្ចឹមសត្វ រំពឹងថានឹងបន្តងើបវិញបណ្តើរៗ ដោយសារបច្ច័យនៃវិធានការអន្តរាគមន៍របស់រាជរដ្ឋាភិបាលលើការនាំចូលសាច់បង្កក និងបទប្បញ្ញត្តិពាក់ព័ន្ធ ដែលនឹងលើកទឹកចិត្តការចិញ្ចឹមក្នុងស្រុក គួបផ្សំនឹងការកើនឡើងនៃតម្រូវការក្នុងស្រុក ខណៈអនុវិស័យនេសាទ ត្រូវបានព្យាករថានឹងមានកំណើនល្អ ក្រោមការរំពឹងទុកនូវកំណើនផលចាប់ទឹកសាប ដោយសារការបន្តអនុវត្តគោលនយោបាយបង្ក្រាបបទល្មើសនេសាទ ស្របពេលដែលការវិនិយោគក្នុងវារីវប្បកម្មត្រូវបានរំពឹងថានឹងងើបសន្សឹមៗ ដោយសារការអនុវត្តវិធានការរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ តាមរយៈការដោះស្រាយបញ្ហាប្រឈមជារចនាសម្ព័ន្ធ, ការគាំទ្រផ្នែកហិរញ្ញប្បទាន, ការផ្សព្វផ្សាយបច្ចេកទេស និងការប្រើប្រាស់ពូជត្រីប្រកបដោយប្រសិទ្ធភាពខ្ពស់ និងគុណភាព។

## ជំពូក ៣. ក្របខ័ណ្ឌថវិកាឆ្នាំ ២០២៦

ផ្អែកលើមូលដ្ឋានក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងការវិវត្តជាក់ស្តែងនៃស្ថានភាពហិរញ្ញវត្ថុសាធារណៈ ព្រមទាំងក្នុងបរិការណ៍នៃភាពមិនប្រាកដប្រជាកាន់តែខ្ពស់, **គោលនយោបាយហិរញ្ញវត្ថុសាធារណៈ**សម្រាប់រយៈពេលមធ្យមខាងមុខ ត្រូវបានរៀបចំឡើងដោយប្រកាន់យកនូវ **«ជំហរគោលនយោបាយពង្រឹងសក្តិសិទ្ធិភាពថវិកា ដើម្បីទ្រទ្រង់ស្ថិរភាព និងកំណើន»**។ អនុវត្តតាមគោលជំហរនេះ រាជរដ្ឋាភិបាលផ្តោតជាសំខាន់លើការបន្តពង្រឹងសក្តិសិទ្ធិភាពថវិកា ទាំងកម្រិតវិភាជន៍និងកម្រិតប្រតិបត្តិការ តាមរយៈការបន្តធ្វើអាទិភាវូបនីយកម្មចំណាយ ដោយក្នុងនោះក្របខ័ណ្ឌចំណាយសាធារណៈត្រូវបានរៀបចំឡើងដើម្បីតម្រង់ទិសធនធានទៅកាន់មុខសញ្ញាដែលជាអាទិភាពសំខាន់ៗចំពោះមុខ ជាពិសេសគឺការពង្រឹងសមត្ថភាពការពារអធិបតេយ្យជាតិនិងបូរណភាពទឹកដី ការរក្សាលំនឹង

សង្គម-សេដ្ឋកិច្ចនិងជីវភាពប្រជាជន ការលើកកម្ពស់សមធម៌សង្គម និងការបន្តទ្រទ្រង់ដំណើរការនៃកិច្ចអភិវឌ្ឍសង្គម ព្រមទាំងការធានានិរន្តរភាពប្រតិបត្តិការការងាររបស់រាជរដ្ឋាភិបាល ស្របតាមទិសដៅជាយុទ្ធសាស្ត្រដែលបានដាក់ចេញនៅក្នុង «យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១» របស់រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា។ ក្នុងន័យនេះ ក្របខ័ណ្ឌថវិកាឆ្នាំ ២០២៦ ត្រូវបានកំណត់ដូចខាងក្រោម៖

| **សូចនាករថវិកា** | **២០២៤** | | **២០២៥** | **២០២៦** |
|---|---|---|---|---|
| | ច្បាប់ | អនុវត្ត | ច្បាប់ | ច្បាប់ |
| I. ចំណូលសរុបថវិកាជាតិ (%ផ.ស.ស.) | *១៧,២២* | *១៥,៨៧* | *១៥,៦៣* | ***១៥,០៩*** |
| ចំណូលក្នុងប្រទេសថវិកាជាតិ (%ផ.ស.ស.) | *១៦,៨៥* | *១៥,១៦* | *១៥,៣២* | ***១៤,៨៥*** |
| - *ចំណូលចរន្តថវិកាជាតិ (%ផ.ស.ស.)* | *១៦,៥៨* | *១៤,៨២* | *១៥,០៣* | ***១៤,៥៦*** |
| II. ចំណាយសរុបថវិកាជាតិ (%ផ.ស.ស.) | *១៩,៦៦* | *១៧,៦៦* | *១៨,៧៧* | ***១៨,៨៥*** |
| - *ចំណាយចរន្តថវិកាជាតិ (%ផ.ស.ស.)* | *១៣,៧១* | *១២,៤៣* | *១២,៨៨* | ***១២,៥៩*** |
| អតិរេកចរន្ត (%ផ.ស.ស.) | *២,៨៧* | *២,៤០* | *២,១៤* | ***១,៩៨*** |
| III. ឱនភាពសរុប (%ផ.ស.ស.) | *-២,៤៤* | *-១,៩៣* | *-៣,១៤* | ***-៣,៧៦*** |
| IV. តម្រូវការហិរញ្ញប្បទាន | *៣,៥៦* | *២,៨៧* | *៤,៣៤* | ***៥,១៩*** |
| - ឱនភាពសរុបនៃថវិកាថ្នាក់ជាតិ | *២,៤៤* | *១,៩៣* | *៣,១៤* | ***៣,៧៦*** |
| - ការទូទាត់ការខ្ចី | *១,១២* | *០,៩៣* | *១,២០* | ***១,២៣*** |
| - ការបង្វិលសងអាករលើតម្លៃបន្ថែម (%ផ.ស.ស.) | *០,០* | *០,០* | *០,០* | ***០,២១*** |
| V. ប្រភពហិរញ្ញប្បទាន | *៣,៥៦* | *២,៨៧* | *៤,៣៤* | ***៥,១៩*** |
| - ហិរញ្ញប្បទានក្រៅប្រទេស | *៣,៣២* | *៣,១៧* | *៤,០៩* | ***៤,០១*** |
| - ហិរញ្ញប្បទានក្នុងប្រទេស | *០,២៣* | *-០,៣០* | *០,២៥* | ***១,១៨*** |

- **<u>ចំណូលសរុបថវិការដ្ឋ</u>** ត្រូវបានគ្រោង ១៥,០៩% នៃ ផ.ស.ស. ស្មើនឹងចំនួន ៣២ ៧៤៧ ប៊ីលានរៀល។
- **<u>ចំណាយសរុបថវិការដ្ឋ</u>** ត្រូវបានគ្រោង ១៨,៨៥% នៃ ផ.ស.ស. ស្មើនឹងចំនួន ៤០ ៩១៣ ប៊ីលានរៀល។
- **<u>អតិរេកថវិកាចរន្ត</u>** អាចរក្សាបានក្នុងកម្រិតប្រមាណ ១,៩៨% នៃ ផ.ស.ស.។
- **<u>ឱនភាពថវិកាសរុប</u>** ស្មើនឹង -៣,៧៦% នៃ ផ.ស.ស.។

ដូចនេះ រាជរដ្ឋាភិបាល មានតម្រូវការហិរញ្ញប្បទានក្នុងទំហំ **៥,១៩% នៃ ផ.ស.ស.** ដោយក្នុងនោះ បានគិតបញ្ចូលទាំងការគ្រោងការទូទាត់ការខ្ចីក្នុងទំហំ **១,២៣% នៃ ផ.ស.ស.** និងការបង្វិលសងអាករលើតម្លៃបន្ថែមក្នុងទំហំ **០,២១% នៃ ផ.ស.ស.** ផងដែរ។ តម្រូវការហិរញ្ញប្បទាននេះ ត្រូវបានបំពេញតុល្យភាពដោយៈ **(១)**-ហិរញ្ញប្បទានក្រៅប្រទេសដែលមានប្រភពពីការខ្ចីក្នុងទំហំ ៤,០១% នៃ ផ.ស.ស. ក្នុងនោះ៖ មូលនិធិទ្រទ្រង់ថវិកាក្នុងទំហំ ១% នៃ ផ.ស.ស. និងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសក្នុងទំហំ ៣,០១% នៃ ផ.ស.ស. និង **(២)**-ហិរញ្ញប្បទានក្នុងប្រទេស តាមរយៈការបោះផ្សាយមូលបត្ររដ្ឋក្នុងទំហំ ០,៩៧% នៃ ផ.ស.ស. ត្រូវជា ២ ១១៤ ប៊ីលានរៀល សមមូលនឹងប្រមាណ ៥២៤ លានដុល្លារអាម៉េរិក និងការបង្វិលសងអាករលើតម្លៃបន្ថែមក្នុងទំហំ ០,២១% នៃ ផ.ស.ស។



## ៣.១. ស្ថានភាពចំណូលថវិការដ្ឋ

ក្នុងក្របខ័ណ្ឌនៃគោលដៅខាងលើ រាជរដ្ឋាភិបាលត្រូវបង្កើនចំណូលសរុបថវិការដ្ឋឱ្យស្មើនឹង **៣២ ៧៤៧ ប៊ីលានរៀល** ត្រូវជា **១៥,០៩%** នៃ ផ.ស.ស. កើនឡើង ៣,៦% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៥ ក្នុងនោះ : **១)-ចំណូលចរន្តថវិការដ្ឋ**ឱ្យស្មើនឹង **៣១ ៦១០ ប៊ីលានរៀល** (ដែលរួមមាន ចំណូលសារពើពន្ធ **២៧ ៣២៩ ប៊ីលានរៀល** និង ចំណូលមិនមែនសារពើពន្ធ **៤ ២៨១ ប៊ីលានរៀល**) ត្រូវជា **១៤,៥៦%** នៃ ផ.ស.ស.និង **២)- ចំណូលផ្សេងៗ** ត្រូវបានគ្រោង **១ ១៣៧ ប៊ីលានរៀល**, ត្រូវជា ០,៥២% នៃ ផ.ស.ស.។

| ចំណូលថវិកា (លានរៀល) | ២០២៥ | | ២០២៦ | | ច្ប២៦/ ច្ប២៥ |
|---|---|---|---|---|---|
| | ច្បាប់ | % ផសស | ច្បាប់ | % ផសស | |
| **សរុបចំណូលថវិការដ្ឋ** | **31.598.073** | **15,63%** | **32.746.600** | **15,09%** | **103,6%** |
| • ថ្នាក់ជាតិ | 29.045.863 | 14,36% | 30.286.114 | 13,95% | 104,3% |
| • ថ្នាក់ក្រោមជាតិ | 2.552.210 | 1,26% | 2.460.486 | 1,13% | 96,4% |
| **១. ចំណូលចរន្តថវិការដ្ឋ** | **30.388.877** | **15,03%** | **31.610.021** | **14,56%** | **104,0%** |
| **ក. ចំណូលសារពើពន្ធថវិការដ្ឋ** | **26.418.110** | **13,06%** | **27.328.912** | **12,59%** | **103,4%** |
| - ថ្នាក់ជាតិ | 24.199.371 | 11,97% | 25.341.342 | 11,67% | 104,7% |
| - ថ្នាក់ក្រោមជាតិ | 2.218.739 | 1,10% | 1.987.570 | 0,92% | 89,6% |
| **ខ. ចំណូលមិនមែនសារពើពន្ធថវិការដ្ឋ** | **3.970.767** | **1,96%** | **4.281.109** | **1,97%** | **107,8%** |
| - ថ្នាក់ជាតិ | 3.670.032 | 1,81% | 3.864.095 | 1,78% | 105,3% |
| - ថ្នាក់ក្រោមជាតិ | 300.735 | 0,15% | 417.014 | 0,19% | 138,7% |
| **២. ចំណូលផ្សេងៗ** | **1.209.196** | **0,60%** | **1.136.579** | **0,52%** | **94,0%** |
| **- ថវិកាថ្នាក់ជាតិ** | **1.176.460** | **0,58%** | **1.080.677** | **0,50%** | **91,9%** |
| • ក្នុងប្រទេស | 549.980 | 0,27% | 564.540 | 0,26% | 102,6% |
| • ក្រៅប្រទេស | 626.480 | 0,31% | 516.137 | 0,24% | 82,4% |
| **- ថវិកាថ្នាក់ក្រោមជាតិ** | **32.736** | **0,02%** | **55.902** | **0,03%** | **170,8%** |

## ៣.២. ស្ថានភាពចំណាយថវិការដ្ឋ

សម្រាប់ឆ្នាំ ២០២៦ ចំណាយសរុបថវិការដ្ឋ ត្រូវបានគ្រោងចំនួន **៤០ ៩១៣ ប៊ីលានរៀល**, ត្រូវជា **១៨,៨៥%**នៃ ផ.ស.ស., កើន ៧,៨%ធៀបនឹងច្បាប់ឆ្នាំ ២០២៥, ដែលក្នុងនោះ៖ (១)-**ចំណាយចរន្តថវិការដ្ឋ**មានចំនួន **២៧ ៣១៧ ប៊ីលានរៀល**, ត្រូវជា **១២,៥៩%** នៃ ផ.ស.ស., **និង** (២)-**ចំណាយមូលធនថវិការដ្ឋ** មានចំនួន **១៣ ៥៩៦ ប៊ីលានរៀល**, ត្រូវជា **៦,២៦%** នៃ ផ.ស.ស.។

| ចំណាយថវិកា (លានរៀល) | ២០២៥ | | ២០២៦ | | ច្ប២៦/ច្ប២៥ |
|---|---|---|---|---|---|
| | ច្បាប់ | % ផសស | ច្បាប់ | % ផសស | |
| **សរុបចំណាយថវិការដ្ឋ** | **37.950.385** | **18,77%** | **40.913.144** | **18,85%** | **107,8%** |
| • ថ្នាក់ជាតិ | 35.398.175 | 17,50% | 38.452.658 | 17,72% | 108,6% |
| • ថ្នាក់ក្រោមជាតិ | 4.421.580 | 2,19% | 4.275.380 | 1,97% | 96,7% |
| **១. ចំណាយចរន្តថវិការដ្ឋ** | **26.054.019** | **12,88%** | **27.317.377** | **12,59%** | **104,8%** |
| **១.១. ថ្នាក់ជាតិ** | **23.901.809** | **11,82%** | **25.240.891** | **11,63%** | **105,6%** |
| • បន្ទុកបុគ្គលិក | 10.612.122 | 5,25% | 10.717.415 | 4,94% | 101,0% |
| • ក្រៅបន្ទុកបុគ្គលិក | 13.289.687 | 6,57% | 14.523.477 | 6,69% | 109,3% |
| **១.២. ថ្នាក់ក្រោមជាតិ** | **4.021.580** | **1,99%** | **3.891.380** | **1,79%** | **96,8%** |
| • បន្ទុកបុគ្គលិក | 902.061 | 0,45% | 911.020 | 0,42% | 101,0% |
| • ក្រៅបន្ទុកបុគ្គលិក | 3.119.519 | 1,54% | 2.980.361 | 1,37% | 95,5% |
| **២. ចំណាយមូលធនថវិការដ្ឋ** | **11.896.366** | **5,88%** | **13.595.767** | **6,26%** | **114,3%** |
| - វិនិយោគសាធារណៈដោយហិរញ្ញប្ប-ទានក្នុងប្រទេស | 5.025.096 | 2,48% | 6.546.227 | 3,02% | 130,3% |
| + ក្នុងនោះចំណាយមូលធនថ្នាក់ក្រោមជាតិ | 400.000 | 0,20% | 384.000 | 0,18% | 96,0% |
| - វិនិយោគសាធារណៈដោយហិរញ្ញប្ប-ទានក្រៅប្រទេស | 6.871.270 | 3,40% | 7.049.540 | 3,25% | 102,6% |

## ៣.៣. ចំណាយថវិកាថ្នាក់ជាតិ

| ចំណាយតាមវិស័យ (លានរៀល) | ២០២៥ | | ២០២៦ | | ច្បា២៦/ច្បា២៥ |
|---|---|---|---|---|---|
| | ច្បាប់ | % ផសស | ច្បាប់ | % ផសស | |
| **១. វិស័យរដ្ឋបាលទូទៅ** | **3.395.996** | **1,68%** | **3.408.280** | **1,57%** | **100,4%** |
| **ក. ចំណាយចរន្ត** | **3.239.992** | **1,60%** | **3.188.609** | **1,47%** | **98,4%** |
| -បន្ទុកបុគ្គលិក | 914.012 | 0,45% | 940.733 | 0,43% | 102,9% |
| -ក្រៅបន្ទុកបុគ្គលិក | 2.325.980 | 1,15% | 2.247.876 | 1,04% | 96,6% |
| **ខ. ចំណាយមូលធន** | **156.004** | **0,08%** | **219.671** | **0,10%** | **140,8%** |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 6.615 | 0,003% | 18.670 | 0,01% | 282,2% |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 149.389 | 0,07% | 201.001 | 0,09% | 134,5% |
| **២. វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ** | **5.792.447** | **2,86%** | **5.741.348** | **2,65%** | **99,1%** |
| **ក. ចំណាយចរន្ត** | **5.625.026** | **2,78%** | **5.686.612** | **2,62%** | **101,1%** |
| -បន្ទុកបុគ្គលិក | 4.560.594 | 2,26% | 4.579.130 | 2,11% | 100,4% |
| -ក្រៅបន្ទុកបុគ្គលិក | 1.064.432 | 0,53% | 1.107.482 | 0,51% | 104,0% |
| **ខ. ចំណាយមូលធន** | **167.421** | **0,08%** | **54.736** | **0,03%** | **32,7%** |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 16.000 | 0,01% | 17.040 | 0,01% | 106,5% |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 151.421 | 0,07% | 37.696 | 0,02% | 24,9% |
| **៣. វិស័យសង្គមកិច្ច** | **10.500.551** | **5,19%** | **10.988.543** | **5,06%** | **104,6%** |
| **ក. ចំណាយចរន្ត** | **9.432.616** | **4,66%** | **9.853.042** | **4,54%** | **104,5%** |
| -បន្ទុកបុគ្គលិក | 4.448.466 | 2,20% | 4.488.992 | 2,07% | 100,9% |

| ចំណាយតាមវិស័យ (លានរៀល) | ២០២៥ | | ២០២៦ | | ច្បា២៦/ ច្បា២៥ |
|---|---|---|---|---|---|
| | ច្បាប់ | % ផសស | ច្បាប់ | % ផសស | |
| -ក្រៅបន្ទុកបុគ្គលិក | 4.984.151 | 2,46% | 5.364.050 | 2,47% | 107,6% |
| **ខ. ចំណាយមូលធន** | **1.067.935** | **0,53%** | **1.135.501** | **0,52%** | **106,3%** |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 152.334 | 0,08% | 152.684 | 0,07% | 100,2% |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 915.601 | 0,45% | 982.817 | 0,45% | 107,3% |
| **៤. វិស័យសេដ្ឋកិច្ច** | **8.037.792** | **3,97%** | **8.234.061** | **3,79%** | **102,4%** |
| **ក. ចំណាយចរន្ត** | **1.837.509** | **0,91%** | **1.857.850** | **0,86%** | **101,1%** |
| -បន្ទុកបុគ្គលិក | 689.050 | 0,34% | 708.560 | 0,33% | 102,8% |
| -ក្រៅបន្ទុកបុគ្គលិក | 1.148.459 | 0,57% | 1.149.290 | 0,53% | 100,1% |
| **ខ. ចំណាយមូលធន** | **6.200.283** | **3,07%** | **6.376.210** | **2,94%** | **102,8%** |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 545.424 | 0,27% | 548.184 | 0,25% | 100,5% |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 5.654.859 | 2,80% | 5.828.027 | 2,68% | 103,1% |

### ៣.៣.១. ចំណាយចរន្តថវិកាថ្នាក់ជាតិ

#### ក. ចំណាយបន្ទុកបុគ្គលិក

ចំណាយលើបន្ទុកបុគ្គលិក ត្រូវបានគ្រោងចំនួន **១០ ៧១៧ ប៊ីលានរៀល** សម្រាប់ : (១)-បៀវត្ស និងការដំឡើងឋានន្តរសក្តិ និងថ្នាក់ប្រចាំឆ្នាំរបស់មន្ត្រីរាជការស៊ីវិល និងកង-កម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និង (២)-ការជ្រើសរើសមន្ត្រីក្របខ័ណ្ឌថ្មីជំនួសអ្នកចូល-និវត្តន៍ក្នុងឆ្នាំ ២០២៥។ ទន្ទឹមនេះ, **បៀវត្សអប្បបរមារបស់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ** ក្នុងឆ្នាំ ២០២៦ មានស្ថានភាពដូចខាងក្រោម៖

- បៀវត្សមន្ត្រីរាជការស៊ីវិលទូទៅ ស្មើនឹង **១ ៣៩៦ ៩៥០ រៀល**;

- បៀវត្សគ្រូបង្រៀន និង គ្រូពេទ្យ ស្មើនឹង **១ ៤៩៦ ៩៥០ រៀល**;

- បៀវត្សនគរបាលជាតិ (ពលបាលត្រី) ស្មើនឹង **១ ៤៨៣ ៩២៧ រៀល** (ដោយគិតបញ្ចូលទាំងរបបអង្គរ);

- បៀវត្សយោធិន (ពលទោ) ស្មើនឹង **១ ៣៤៦ ៥៥០ រៀល** (ដោយមិនទាន់គិតបញ្ចូលរបបអង្គរ) ហើយបើគិតបញ្ចូលទាំងរបបអង្គរ ស្មើនឹង **១ ៤១៩ ៦៧៥ រៀល**។

សម្រាប់ឆ្នាំ ២០២៦ **មន្ត្រីជាប់កិច្ចសន្យា**ទទួលបានប្រាក់ឧបត្ថម្ភប្រចាំខែចំនួន **៧៩០ ០០០ រៀល**។

**ស្ថានភាពបៀវត្សអប្បបរមារបស់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធឆ្នាំ ២០២៦**




លើសពីនេះ រាជរដ្ឋាភិបាលបានគ្រោងថវិកាចំនួន ១៤០ ប៊ីលានរៀល សមមូលនឹងប្រមាណ ៣៥ លានដុល្លារអាម៉េរិក ដោយឡែកផ្សេងទៀត សម្រាប់បន្តអនុវត្ត **ការកែទម្រង់រដ្ឋបាលសាធារណៈ** ក្នុងនោះសម្រាប់គាំទ្រ**ប្រព័ន្ធលើកទឹកចិត្តផ្អែកសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ** នៅតាមក្រសួង ស្ថាប័ន ចំនួន ៦០ ប៊ីលានរៀល សមមូលនឹងប្រមាណ ១៥ លានដុល្លារអាម៉េរិក។

ជាមួយគ្នានេះដែរ ដើម្បីលើកកម្ពស់សុខភាពមន្ត្រីរាជការ រាជរដ្ឋាភិបាលក៏បានគ្រោងថវិកាចំនួន **៨៦,២ ប៊ីលានរៀល** ក្នុងកញ្ចប់ថវិការបស់ក្រសួងសុខាភិបាល សម្រាប់ការថែទាំសុខភាពមន្ត្រីរាជការស៊ីវិល នគរបាលជាតិ និងនិវត្តជន ព្រមទាំងបានគ្រោងថវិកាចំនួន **៦ ប៊ីលានរៀល** សម្រាប់បន្តគាំទ្ររបបសន្តិសុខសង្គម ផ្នែកហានិភ័យការងាររបស់មន្ត្រីសាធារណៈផងដែរ។

## ខ. ចំណាយមិនមែនបន្ទុកបុគ្គលិក

ត្រូវបានគ្រោងចំនួន **១៤ ៥២៣ ប៊ីលានរៀល**, មានសមាមាត្រស្មើនឹង ៥៧,៥% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា ៦,៦៩% នៃផ.ស.ស. ឬកើនចំនួន ៩,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៥។

ចំណាយចរន្តថវិកាថ្នាក់ជាតិត្រូវបានវិភាជន៍តាមវិស័យ ហើយនៅកម្រិតក្រសួង ស្ថាប័ននីមួយៗ ត្រូវបានធ្វើការវិភាជបន្តទៅតាមកម្មវិធី អនុកម្មវិធី រហូតដល់ចង្កោមសកម្មភាព ព្រមទាំងឆ្លុះបញ្ចាំងលម្អិតទៅតាមមាតិកាសេដ្ឋកិច្ចនៃចំណាត់ថ្នាក់ថវិកា ដោយផ្អែកលើតម្រូវការ និងអាទិភាពចាំបាច់ដូចខាងក្រោម ៖

**<u>ចំណាយចរន្តវិស័យរដ្ឋបាលទូទៅ ៖</u>**

- ព្រះរាជសកម្មភាពរបស់ព្រះករុណាព្រះមហាក្សត្រ និងសម្តេចព្រះមហាក្សត្រី-វររាជមាតាជាតិខ្មែរ,
- ការអនុវត្តការងារ និងតួនាទីនីតិប្បញ្ញត្តិរបស់រដ្ឋសភា និងព្រឹទ្ធសភា និងការគាំទ្រដល់កិច្ចដំណើរការរបស់អគ្គលេខាធិការដ្ឋានរដ្ឋសភា និងព្រឹទ្ធសភា,
- ការអនុវត្តតួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ,
- ការពង្រឹង និងការពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការអន្តរជាតិនៅក្រៅប្រទេស និងការងារការទូតសេដ្ឋកិច្ច ដើម្បីបន្តលើកកម្ពស់តួនាទីរបស់កម្ពុជាក្នុងកិច្ចការតំបន់ និងនៅលើឆាកអន្តរជាតិ ដោយស្មើសិទ្ធិ និងស្មើភាព ព្រមទាំងបន្តផ្តល់ការគាំទ្រដល់កិច្ចការពារ និងជួយសង្គ្រោះពលករខ្មែរដែលធ្វើការនៅក្រៅប្រទេស ពិសេសស្ត្រីខ្មែរដែលត្រូវរងគ្រោះដោយការឆបោក និងការជួញដូរផ្លូវភេទ,
- ការអនុវត្តតួនាទី និងភារកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត រួមទាំងការអនុវត្តការងារពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត,
- ការងារសម្របសម្រួលលើកិច្ចការទូទៅរបស់គណៈរដ្ឋមន្ត្រី និងការងាររបស់អង្គភាពពាក់ព័ន្ធ ដែលស្ថិតក្រោមទីស្តីការគណៈរដ្ឋមន្ត្រី រួមទាំងការងារកែទម្រង់ច្បាប់ ការគ្រប់គ្រង និងការអភិវឌ្ឍទេសចរណ៍សៀមរាប-អង្គរ ព្រមទាំងការគាំទ្រដល់ការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១,
- ការងារកែទម្រង់រដ្ឋបាលសាធារណៈ ជាពិសេស ការពង្រឹងសមត្ថភាពស្ថាប័ន និងការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ,

- ការងារទាក់ទាញនិងការគ្រប់គ្រងវិនិយោគឯកជន និងការពង្រឹងភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍ,
- ការធ្វើទំនើបកម្ម និងប្រព័ន្ធស្វ័យប្រវត្តិកម្មរដ្ឋបាលសារពើពន្ធ ដើម្បីគាំទ្រដល់កិច្ចសម្រួលពាណិជ្ជកម្ម ការធ្វើធុរកិច្ច ការកៀរគរ និងការគ្រប់គ្រងចំណូល,
- ការធ្វើទំនើបកម្មការគ្រប់គ្រងចំណាយសាធារណៈ និងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដើម្បីបង្កើនប្រសិទ្ធភាពនៃការរៀបចំ ការវិភាជ និងការអនុវត្តថវិកា,
- ការងាររៀបចំ អនុវត្ត និងត្រួតពិនិត្យគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច រួមទាំងការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល ការកសាងនិងការអភិវឌ្ឍសេដ្ឋកិច្ចធុរកិច្ច និង សង្គមឌីជីថល,
- ការគាំទ្រដល់ការអនុវត្តគម្រោងអភិវឌ្ឍន៍ និងប្រតិបត្តិការនៃថ្នាលចុះឈ្មោះប្រជាជនក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលជាផ្នែកមួយការអនុវត្តយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ,
- ការបន្តគាំទ្រដល់មូលនិធិអភិវឌ្ឍន៍ជំនាញ,
- ការបន្តចុះបញ្ជី និងការផ្តល់បណ្ណកម្មសិទ្ធិដីធ្លី ទាំងដីឯកជន ដីរដ្ឋ និងដីសហគមន៍,
- ការដោះស្រាយទំនាស់ដីធ្លី និងការបែងចែកដីសម្បទានសង្គមកិច្ច,
- ការពង្រឹងការគ្រប់គ្រងវិស័យសំណង់ ការរៀបចំប្លង់គោល និងនគរូបនីយកម្ម,
- ការអនុវត្តតួនាទីសវនកម្ម លើការប្រើប្រាស់ធនធានសាធារណៈ,
- ការធ្វើអធិការកិច្ច និងការងារដោះស្រាយបណ្តឹង,
- ការអភិវឌ្ឍប្រព័ន្ធស្ថិតិជាតិ,
- សកម្មភាពបោសសម្អាតមីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះ,
- ការបញ្ជូនកងកម្លាំងកម្ពុជាទៅចូលរួមក្នុងបេសកកម្មថែរក្សាសន្តិភាពនៅក្រោមឆ័ត្ររបស់អង្គការសហប្រជាជាតិ,
- ការប្រយុទ្ធប្រឆាំងអំពើពុករលួយ, និង
- សកម្មភាពរបស់វេទិកាសម្ព័ន្ធសង្គមស៊ីវិល ដើម្បីពង្រឹងភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ក្នុងកិច្ចអភិវឌ្ឍប្រទេស និងការលើកស្ទួយសិទ្ធិមនុស្ស។

**ចំណាយចរន្តវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ៖**

- ការពង្រឹងសមត្ថភាពការពារអធិបតេយ្យជាតិ និងបូរណភាពទឹកដី សន្តិសុខ និងសុវត្ថិភាព និងកិច្ចប្រតិបត្តិការសង្គ្រោះប្រជាពលរដ្ឋពេលមានគ្រោះមហន្តរាយផ្សេងៗ,
- ការយកចិត្តទុកដាក់លើជីវភាព និងសុខុមាលភាពកងកម្លាំងប្រដាប់អាវុធ រួមទាំងការហ្វឹកហ្វឺន ព្រមទាំងការគ្រប់គ្រង និងថែទាំយុទ្ធោបករណ៍និងសម្ភារបច្ចេកទេស,
- ការអនុវត្តកិច្ចការសន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈ ការគ្រប់គ្រងសុវត្ថិភាពចរាចរណ៍ផ្លូវគោក ការអនុវត្តគោលនយោបាយប្រយុទ្ធប្រឆាំងគ្រឿងញៀន,
- ការអនុវត្តកិច្ចការសន្តិសុខមិនប្រពៃណី ដូចជា៖ ឧក្រិដ្ឋកម្មឆ្លងដែន ការជួញដូរគ្រឿងញៀន ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ស្ត្រី និងកុមារ ព្រមទាំងអំពើឃោរឃៅ និងអំពើអមនុស្សធម៌,
- ការផលិតលិខិតឆ្លងដែន និងប្រតិបត្តិការផលិតអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរជូនប្រជាពលរដ្ឋ ព្រមទាំងការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យព្រំដែន,
- ការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ សង្កាត់មានសុវត្ថិភាព",
- ការអភិវឌ្ឍចំណេះដឹង និងជំនាញវិជ្ជាជីវៈជូនដល់កងកម្លាំងនគរបាលជាតិ,
- កិច្ចដំណើរការសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងការពង្រឹងការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈនៅរដ្ឋបាលមូលដ្ឋាន,
- កិច្ចដំណើរការគ្រប់គ្រងពន្ធនាគារ,
- ការពង្រឹង និងការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌តាមរយៈការអនុវត្តយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ បន្ថែមលើយន្តការដែលមានស្រាប់ ព្រមទាំងការអនុវត្តយន្តការសម្រាប់ជំរុញ និងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការឱ្យបានឆាប់រហ័ស និងការត្រួតពិនិត្យ និងការដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ,
- កិច្ចដំណើរការរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ និងរដ្ឋបាលតុលាការ ដើម្បីលើកកម្ពស់សេវាយុត្តិធម៌ និងពង្រឹងនីតិរដ្ឋនៅកម្ពុជា ព្រមទាំងការបន្តគាំទ្រដល់កំណែទម្រង់ប្រព័ន្ធយុត្តិធម៌,

- ការរៀបចំប្រព័ន្ធគ្រប់គ្រងសំណុំរឿងក្ដីនៅតាមសាលាជម្រះក្ដី និងការពង្រឹងការគ្រប់គ្រងទិន្នន័យសំណុំរឿងព្រហ្មទណ្ឌ និងរដ្ឋប្បវេណី,
- ការបណ្ដុះបណ្ដាលធនធានមនុស្សក្នុងវិស័យយុត្តិធម៌ ជាពិសេស ចៅក្រមព្រះរាជអាជ្ញា ក្រឡាបញ្ជី អាជ្ញាសាលា និងសាការី,
- ការផ្ដល់សេវាការពារក្ដីដោយឥតគិតថ្លៃជូនប្រជាពលរដ្ឋក្រីក្រ តាមរយៈការផ្ដល់ថវិកាការពារក្ដី ជូនគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, និង
- សកម្មភាពការងារពាក់ព័ន្ធនឹងកិច្ចការព្រំដែន ការចុះវាស់វែង ការថែទាំ និងការបោះបង្គោលព្រំដែន។

<u>**ចំណាយចរន្តវិស័យសង្គមកិច្ច**</u> ៖

អាទិភាពសំខាន់ក្នុងវិស័យនេះ ត្រូវបានផ្ដោតទៅលើ **ការអភិវឌ្ឍមនុស្ស** ដែលត្រូវបានចាត់ទុកថាជា **អាទិភាពទី១** នៅក្នុងចំណោមអាទិភាពគន្លឹះទាំង៥ របស់រាជរដ្ឋាភិបាល តាមរយៈការបន្តផ្ដល់ការគាំទ្រទៅលើកម្មវិធី និងសកម្មភាពការងារជាអាទិភាព មានជាអាទិ៍ ៖

**ទី១-ការលើកកម្ពស់គុណភាពអប់រំ និងការបន្តគាំទ្រដល់ការពង្រឹង និងពង្រីកការទទួលបានសេវាអប់រំ ព្រមទាំងការអប់រំកាយ និងកីឡា តាមរយៈ ៖**

- ការផ្ដល់អាហារូបករណ៍ដល់គរុសិស្ស និងនិស្សិត និងការប្រែក្លាយជាបណ្ដើរៗពីសាលាគរុកោសល្យ និងវិក្រឹតការខេត្ត និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគឱ្យទៅជាវិទ្យាស្ថានគរុកោសល្យភូមិភាគ ដើម្បីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន,
- ការផ្ដល់ថវិកាដំណើរការសាលារៀនសាធារណៈ សាលាគរុកោសល្យនិងវិក្រឹត្យការខេត្ត និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្ត ដើម្បីលើកកម្ពស់សេវាអប់រំតាមសាលារៀន,
- ការកែទម្រង់កម្មវិធីសិក្សា និងការបោះពុម្ពសៀវភៅសិក្សាគោល ព្រមទាំងការបែងចែក និងការបញ្ជូនឱ្យទាន់ពេល និងស្របតាមមុខវិជ្ជាដែលសាលារៀននីមួយៗមានតម្រូវការជាក់ស្ដែង,
- ការអនុវត្តកម្មវិធីផ្ដល់អាហារតាមសាលារៀន គ្របដណ្ដប់លើសាលារៀនគោលដៅចំនួន ៨១៦ ក្នុងខេត្តចំនួន ១០ និងមានសិស្សទទួលអាហារច្រើនជាង ២៣ ម៉ឺននាក់,
- ការបន្តផ្ដល់អាហារូបករណ៍ប្រចាំឆ្នាំដល់សិស្សមកពីគ្រួសារមានបណ្ណសមធម៌នៅគ្រប់កម្រិត ដើម្បីជួយកាត់បន្ថយអត្រាបោះបង់ការសិក្សារបស់សិស្ស និង

សម្រាលបន្ទុកចំណាយរបស់មាតាបិតា និងអាណាព្យាបាលសិស្ស ពិសេសដើម្បីផ្តល់ឱកាសដល់សិស្សក្រីក្រឱ្យទទួលបាននូវការអប់រំប្រកបដោយសមធម៌ និងបរិយាបន្ន តាមរយៈយន្តការកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ។ ទន្ទឹមនេះ សិស្សដែលមិនមែនមកពីគ្រួសារមានបណ្ណសមធម៌ ដែលធ្លាប់ទទួលបានអាហារូបករណ៍កន្លងមក ក៏ត្រូវបានផ្តល់អាហារូបករណ៍រហូតបញ្ចប់ភូមិសិក្សានីមួយៗផងដែរ ដោយផ្តោតលើសិស្សពិការ សិស្សជាកូនកំព្រា សិស្សជនជាតិភាគតិច និងសិស្សពូកែ,

- ការបន្តសាងសង់បង្គន់អនាម័យ និងប្រព័ន្ធទឹកស្អាតនៅតាមសាលារៀន ដើម្បីផ្តល់ភាពងាយស្រួលដល់ការរៀនសូត្ររបស់កុមារី និងយុវតី ក៏ដូចជាសុខុមាលភាពសិស្សជាទូទៅ,
- ការលើកកម្ពស់អនាម័យសាលារៀននៅរាជធានីភ្នំពេញ តាមរយៈការបន្ថែមថវិកាសម្រាប់បង់ថ្លៃសេវាប្រមូលសំរាមពីគ្រប់សាលារៀននៅក្នុងរាជធានីភ្នំពេញ,
- ការបន្តពង្រឹង និងពង្រីកសាលារៀនជំនាន់ថ្មី នៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា ព្រមទាំងវិទ្យាល័យ ចំណេះទូទៅ និងបច្ចេកទេស,
- ការអភិវឌ្ឍជំនាញទន់ដល់យុវជន តាមរយៈការគាំទ្រការអនុវត្តកម្មវិធី "មនសិការពលរដ្ឋល្អ" ដើម្បីកសាង និងអភិវឌ្ឍន៍ធនធានយុវជនកម្ពុជាប្រកបដោយសមត្ថភាព បំណិនជីវិត គំនិតច្នៃប្រឌិត មនសិការស្នេហាជាតិ និងភាពជាពលរដ្ឋល្អ,
- ការពង្រីកការអនុវត្តស្តង់ដាសាលារៀនគំរូ តាមរយៈលេខាធិការដ្ឋានគណៈ-កម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងវិស័យអប់រំ (គ.វ.អ.),
- ការបន្តលើកកម្ពស់គុណភាពឧត្តមសិក្សា ពិសេសការគាំទ្រដល់ការសិក្សា និងស្រាវជ្រាវលើមុខជំនាញវិទ្យាសាស្ត្រពិត បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា និងការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍ,
- ការបន្តលើកកម្ពស់ការអប់រំកាយ និងកីឡា ជាពិសេសការផ្តល់ការហ្វឹកហាត់ដើម្បីត្រៀមចូលរួមការប្រកួតកីឡាលក្ខណៈតំបន់ និងអន្តរជាតិ,
- ការបន្តកសាងអគារសិក្សា និងការជួសជុលថែទាំអគារសិក្សា រួមទាំង ការបំពាក់តុកៅអី តាមសាលារៀន។

**ទី២-ការបន្តផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍជំនាញ ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារ ពិសេសនៅក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម និងការអភិវឌ្ឍវិស័យការងារ និងការរក្សាសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈមានជាអាទិ៍ ៖**

- ការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈគ្រប់កម្រិត ដោយផ្តល់អាទិភាពជាពិសេសលើការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈកម្រិតទី ១ (C1) ដោយផ្តល់អាហារូបករណ៍ដល់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យនៅទូទាំងប្រទេស និងពលករវិលត្រឡប់ពីប្រទេសថៃ ដើម្បីជួយពួកគេឱ្យបានចូលទីផ្សារការងារក្នុងស្រុកបានឆាប់,
- ការពង្រឹង និងការជំរុញការងារប្រព័ន្ធជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ពីចម្ងាយ ឬតាមអនឡាញ និងប្រព័ន្ធជាតិវាយតម្លៃទទួលស្គាល់ការសិក្សាពីចម្ងាយ សម្រាប់ការវាយតម្លៃផ្អែកលើសមត្ថភាព និងគុណវុឌ្ឍិជាតិកម្ពុជា,
- ការបន្តអភិវឌ្ឍកញ្ចប់ស្តង់ដាបណ្តុះបណ្តាល និងកញ្ចប់សិក្សាផ្អែកលើសមត្ថភាព ព្រមទាំងការពង្រឹងសមត្ថភាព និងគុណភាពគ្រូបច្ចេកទេស,
- ការពង្រីក និងការជួសជុលហេដ្ឋារចនាសម្ព័ន្ធរបស់គ្រឹះស្ថានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស ពិសេសគ្រឹះស្ថានដែលទទួលបានវិញ្ញាបនបត្រអង្គការស្តង់ដាអន្តរជាតិ ដោយរួមទាំងការបន្តបំពាក់សម្ភារៈបរិក្ខារ ឧបករណ៍ពិសោធន៍ថ្មីៗ ដើម្បីរក្សាស្ថិរភាពនៃការផ្គត់ផ្គង់កម្លាំងពលកម្មឱ្យមានជំនាញច្បាស់លាស់ និងលើកកម្ពស់ផលិតភាពអាចឆ្លើយតបតម្រូវការទីផ្សារការងារទាំងបរិមាណ និងគុណភាព,
- ការអនុវត្តតួនាទីរបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ ក្នុងការផ្តល់សេវាស្វែងរកការងារធ្វើជូនយុវជន ទាំងនៅក្នុង និងក្រៅប្រទេស,
- ការពង្រឹងការគ្រប់គ្រងពលករអន្តោប្រវេសន៍ និងការអនុវត្តច្បាប់ការងារ ឱ្យមានប្រសិទ្ធភាពខ្ពស់ និងការបន្តគាំទ្រដល់ការអភិវឌ្ឍលក្ខខណ្ឌការងារ សុវត្ថិភាព និង សុខភាពការងារ,
- ការពង្រឹងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ តាមរយៈការពង្រឹងយន្តការបង្ការទប់ស្កាត់ និងដោះស្រាយវិវាទការងារនៅគ្រប់ដំណាក់កាលយុទ្ធនាការលើកកម្ពស់សិទ្ធិការងារ និងសំវាទសង្គម និងការគ្រប់គ្រងហានិភ័យវិវាទ ការពង្រឹងយន្តការត្រីភាគី និងកិច្ចសន្ទនាសង្គម ព្រមទាំងជំរុញ

យុទ្ធនាការថ្នាក់ជាតិស្ដីពី "សហគ្រាសមួយជាសហគមន៍សុខសាន្តមួយ" និងការពង្រឹងយន្តការបង្ការ ទប់ស្កាត់ និងដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញាជាដើម។

**ទី៣-ការបន្តលើកកម្ពស់គុណភាពសេវាសុខាភិបាល និងការពង្រីកការទទួលបានសេវាថៃទាំសុខភាព ឆ្ពោះទៅរកការគ្រប់ដណ្ដប់សុខភាពជាសកល ពិសេសសម្រាប់ប្រជាជនក្រីក្រ ក្រុមជនងាយរងគ្រោះ ស្ត្រី និងកុមារ តាមរយៈ ៖**

- ការបន្តផ្ដល់ថវិកាសម្រាប់ទ្រទ្រង់ប្រតិបត្តិការមន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព និង ប៉ុស្តិ៍សុខភាពទូទាំងប្រទេស ដោយផ្ទេរថវិកាទៅដល់អ្នកអនុវត្តផ្ទាល់សម្រាប់គម្រោងលើកកម្ពស់គុណភាព និងសមធម៌សុខាភិបាល និងពង្រឹងការអនុវត្តវិធានការគន្លឹះ ក្នុងវិស័យសុខាភិបាលឆ្នាំ ២០២៤-២០២៧ ដែលក្នុងនោះ៖
    - ផ្ដល់ថវិកាចំនួន ៦១០ លានរៀល ដល់មន្ទីរពេទ្យបង្អែកកម្រិត ៣ ទូទាំងប្រទេស សរុបចំនួន ២២ មន្ទីរពេទ្យ,
    - ផ្ដល់ថវិកាចំនួន ៥៧០ លានរៀល ដល់មន្ទីរពេទ្យបង្អែកកម្រិត ២ ទូទាំងប្រទេស សរុបចំនួន ៣៨ មន្ទីរពេទ្យ,
    - ផ្ដល់ថវិកាចំនួន ៥៣០ លានរៀល ដល់មន្ទីរពេទ្យបង្អែកកម្រិត ១ ទូទាំងប្រទេស សរុបចំនួន ៧០ មន្ទីរពេទ្យ,
    - ផ្ដល់ថវិកាចំនួន ៤៥ លានរៀល ដល់មណ្ឌលសុខភាពដែលគ្របដណ្ដប់ប្រជាជនច្រើនជាង ១ ម៉ឺននាក់ សរុបចំនួន ៩២១ មណ្ឌលសុខភាព,
    - ផ្ដល់ថវិកាចំនួន ២៩ លានរៀល ដល់មណ្ឌលសុខភាពដែលគ្របដណ្ដប់ប្រជាជនតិចជាង ១ ម៉ឺននាក់ សរុបចំនួន ៤១៩ មណ្ឌលសុខភាព,
    - ផ្ដល់ថវិកាចំនួន ១០ លានរៀល ដល់ប៉ុស្តិ៍សុខភាពទូទាំងប្រទេសសរុបចំនួន ១២១ ប៉ុស្តិ៍សុខភាព។
- ការបន្តបង្កើនថវិកាសម្រាប់ការផ្គត់ផ្គង់ឱសថ វ៉ាក់សាំង ប្រតិករ និងបរិក្ខារពេទ្យដល់មន្ទីរពេទ្យ រួមទាំងការបង្កើនការឧបត្ថម្ភធនកាន់តែច្រើនដល់មន្ទីរពេទ្យនៅថ្នាក់ជាតិ វិទ្យាស្ថាន និងមន្ទីរពិសោធន៍ ដើម្បីពង្រីក និងពង្រឹងការផ្ដល់សេវាសុខាភិបាល,
- ការបន្តផ្ដល់ថវិកាគាំទ្រ មូលនិធិមន្ទីរពេទ្យគន្ធបុប្ផាកម្ពុជា ដើម្បីធានាបានថាមន្ទីរពេទ្យនេះនៅតែអាចរក្សាបាននូវស្តង់ដាគុណភាព និងការផ្ដល់សេវាព្យាបាលដោយឥតគិតថ្លៃដដែល,

- ការបន្តបង្កើនថវិកាគាំទ្រដល់កម្មវិធីមូលនិធិសមធម៌សុខាភិបាល ដើម្បីផ្តល់សេវាព្យាបាលដោយឥតគិតថ្លៃជូនដល់ ប្រជាជនក្រីក្រ ប្រជាពលរដ្ឋងាយរងហានិភ័យ និងកម្មករនិយោជិតក្រៅប្រព័ន្ធដែលមិនស្ថិតក្រោមបេឡាជាតិ-សន្តិសុខសង្គម (ប.ស.ស.) នៅទូទាំងប្រទេស,
- ការថែទាំសុខភាពមន្ត្រីរាជការស៊ីវិល នគរបាលជាតិ និងអ្នកនៅក្នុងបន្ទុក និងនិវត្តជន ព្រមទាំងរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារចំពោះមន្ត្រីរាជការសាធារណៈ,
- ការបន្តពង្រឹង និងពង្រីកការគ្របដណ្តប់ជាសកលសម្រាប់ការឧបត្ថម្ភមាតុភាព ទាំងក្នុងពេលមានផ្ទៃពោះ ពេលសម្រាល និងទាំងក្រោយពេលសម្រាល ជូនដល់កម្មករនិយោជិត មន្ត្រីរាជការ មន្ត្រីកម្មសិក្សា មន្ត្រីជាប់កិច្ចសន្យា ជាស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ ឆ្នាំ។

**ទី៤-ការបន្តគាំទ្រដល់ការអនុវត្តកម្មវិធីជំនួយសង្គម រួមមាន ៖**

- កម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ដូចជា កម្មវិធីឧបត្ថម្ភគោលសម្រាប់គ្រួសារក្រីក្រទាំងអស់ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនចាស់ជរា (អាយុ ៦០ ឆ្នាំ ឡើង) កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនមានពិការភាព និង កម្មវិធីឧបត្ថម្ភជូនអ្នកផ្ទុកមេរោគអេដស៍ ការផ្តល់អាហារូបករណ៍ដល់សិស្សក្នុងគ្រួសារក្រីក្រទាំងអស់,
- កម្មវិធីជាតិគាំពារសង្គម ដើម្បីជំរុញការចាកចេញពីភាពក្រីក្រ,
- កម្មវិធីស្តារជីវភាពឡើងវិញ សម្រាប់ការផ្លាស់ប្តូរលំនៅឋានរបស់ប្រជាជនទៅក្រុងរុនតាឯកតេជោសែន និង ឃុំពាក់ស្នែងនៃស្រុកអង្គរធំ ខេត្តសៀមរាប។

**ទី៥-ការបន្តផ្តល់ការគាំទ្រដល់អាទិភាពផ្សេងទៀត ក្នុងវិស័យសង្គមកិច្ច រួមមាន ៖**

- របបសន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន,
- ការឧបត្ថម្ភគាំទ្រដល់សមាគមអតីតយុទ្ធជន ការផ្តល់សេវាជូនជនពិការ និងការពង្រីកសកម្មភាពជួយជនពិការក្រីក្រ ចាស់ជរា នៅតាមសហគមន៍,
- ការឧបត្ថម្ភគោលនយោបាយជូនជនរងគ្រោះ ដោយសារការប្រើប្រាស់គ្រឿងញៀន និងការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន,
- ការឧបត្ថម្ភគោលនយោបាយជូនជនវិបល្លាសស្មារតី ជនចំណាកស្រុក ជនអនាថា និង អនីតិជនដែលទំនាស់នឹងច្បាប់ ជាដើម,

- កិច្ចគាំពារបរិស្ថាន និងការងារអភិរក្ស ដូចជា ប្រតិបត្តិការល្បាតរបស់ឧទ្យានុរក្ស ការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងការតាមដានគុណភាពខ្យល់ ព្រមទាំងការលើកកម្ពស់ជីវភាពសហគមន៍តំបន់អភិរក្សធម្មជាតិ,
- ការលើកកម្ពស់យេនឌ័រ និងគណៈកម្មាធិការសីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ព្រមទាំងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ដើម្បីផ្តល់សេវាផ្នែកច្បាប់ចំពោះស្ត្រីក្រីក្ររងគ្រោះ ដោយអំពើហិង្សាគ្រប់ទម្រង់,
- ការពង្រឹង និងពង្រីកការគ្រប់គ្រង និងការផ្សព្វផ្សាយព័ត៌មាន ដើម្បីធានាឱ្យបាននូវការផ្សាយព័ត៌មានប្រកបដោយគុណភាព តាមក្រមសីលធម៌វិជ្ជាជីវៈ,
- ការអភិរក្ស និងអភិវឌ្ឍន៍សម្បត្តិបេតិកភណ្ឌជាតិ ការសិក្សា និងចងក្រងសម្បត្តិវប្បធម៌ អរូបីយនានា ពិសេសការគាំទ្រដល់ការបណ្តុះបណ្តាលសិល្បៈបុរាណ ជំនាញ និងការបន្តជួសជុលប្រាសាទបុរាណដែលប្រឈមនឹងហានិភ័យ,
- ការបណ្តុះបណ្តាលជំនាញដូនតា ដោយមានផ្តល់អាហារូបករណ៍ដល់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ នៅទូទាំងប្រទេស។ ទន្ទឹមនេះ សិស្សមានសមត្ថភាព និងឧបនិស្ស័យ ដែលមិនស្ថិតក្នុងគ្រួសារមានបណ្ណសមធម៌ ក៏ត្រូវបានផ្តល់អាហារូបករណ៍ជូនផងដែរ, និង
- ការបន្តលើកស្ទួយសុខដុមនីយកម្មសាសនានៅកម្ពុជា ពិសេសការបន្តគាំទ្រដល់ពុទ្ធិកសិក្សា នៅគ្រប់កម្រិត និងការផ្សព្វផ្សាយព្រះពុទ្ធសាសនា។

**<u>ចំណាយចរន្តវិស័យសេដ្ឋកិច្ច ៖</u>**

- ការលើកកម្ពស់ផលិតភាពកសិកម្ម និងការជួយគ្រួសារកសិករក្នុងការលើកស្ទួយផលិតផលកសិកម្ម តាមរយៈការរៀបចំឱ្យមានសហគមន៍កសិកម្មទំនើប និងការពង្រាយមន្ត្រីបច្ចេកទេសកសិកម្ម នៅគ្រប់ឃុំ សង្កាត់ ទូទាំងប្រទេស,
- ការលើកកម្ពស់ផលិតភាពស្របតាមស្តង់ដា និងតម្រូវការទីផ្សារ តាមរយៈការផលិតគ្រាប់ពូជស្រូវ ដំណាំ ផលិតកម្មបន្លែ ផលិតកម្មកៅស៊ូប្រកបដោយគុណភាព និងការពង្រឹងយន្តការទីផ្សារ ព្រមទាំងការជំរុញខ្សែច្រវាក់ផលិតកម្មដំណាំ ដូចជា បន្លែសុវត្ថិភាព ម្រេច និងដំណាំស្វាយ ជាដើម ដើម្បីជំរុញការធ្វើពិពិធភាវូបនីយកម្ម និង ពាណិជ្ជូបនីយកម្ម,

- ការជំរុញការចិញ្ចឹមសត្វតាមបច្ចេកទេស និងការទប់ស្កាត់ជំងឺឆ្លងសត្វ ព្រមទាំងការផ្តល់វ៉ាក់សាំង និងបសុឱសថ សម្រាប់ចាក់ការពារនិងព្យាបាលគោ ក្របី ជូនប្រជាកសិករ,
- ការគ្រប់គ្រងសហគមន៍អភិរក្ស និងការគ្រប់គ្រងដែននេសាទ ព្រមទាំងការបង្ក្រាបបទល្មើសនេសាទ ជាពិសេសក្នុងតំបន់ទន្លេសាប និងសមុទ្រ,
- ការជំរុញការអភិវឌ្ឍចម្ការឈើដាំនិងរុក្ខវប្បកម្ម និងការលើកកម្ពស់ការងារដាំឈើសំដៅបង្កើនគម្របព្រៃឈើនៅលើផ្ទៃដីវិចវិល និងបង្កើនទិន្នផលឈើដាំ,
- ការបង្ក្រាបបទល្មើសព្រៃឈើ និងការស្តារព្រៃឈើឡើងវិញ និងការពង្រឹងការគ្រប់គ្រង និងការថែរក្សាសត្វព្រៃ,
- ការជួសជុល និងការថែទាំប្រព័ន្ធធារាសាស្ត្រ ការសម្របសម្រួល ការគ្រប់គ្រងការអភិរក្ស និងការអភិវឌ្ឍតំបន់ទន្លេសាប ការជួសជុល និងការថែទាំស្ថានីយឧតុនិយមស្វ័យប្រវត្តិ និងមិនស្វ័យប្រវត្តិ ការជួសជុល និងការថែទាំម៉ាស៊ីនបូមទឹកចល័ត និងស្ថានីយបូមទឹក ព្រមទាំងការត្រៀមលក្ខណៈឱ្យបានល្អ សម្រាប់កិច្ចអន្តរាគមន៍ជួយប្រជាពលរដ្ឋ ពេលមានគ្រោះរាំងស្ងួត និងទឹកជំនន់ជាយថាហេតុ,
- ការជួសជុល និងការថែទាំផ្លូវ ស្ពាន និងផ្លូវលំជនបទ ព្រមទាំងការស្តារស្រះ និងការជីកស្រះ និងអណ្តូងទឹក,
- ការលើកកម្ពស់អនាម័យតាមសហគមន៍ជនបទ,
- ការគាំទ្រដល់ដំណើរការរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការសម្របសម្រួលការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ,
- ការគ្រប់គ្រងសហគ្រាសធុនតូច និងមធ្យម ការលើកម្ពស់គុណភាពស្តង់ដា និងការអភិវឌ្ឍវិស័យមាត្រាសាស្ត្រ រួមទាំងការគ្រប់គ្រងទិន្នន័យទីតាំងភូមិសាស្ត្ររោងចក្រ,
- ការគ្រប់គ្រង និងការអភិវឌ្ឍវិស័យទឹកស្អាត,
- ការពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងធនធានរ៉ែគ្រប់ប្រភេទ និងការរៀបចំបង្កើតប្រព័ន្ធគ្រប់គ្រងអាជ្ញាបណ្ណអាជីវកម្មរ៉ែសំណង់,
- ការគ្រប់គ្រង និងការអភិវឌ្ឍវិស័យថាមពល,
- ការអភិវឌ្ឍធនធាន និងគោលដៅទាក់ទាញទេសចរណ៍ ព្រមទាំងការគ្រប់គ្រង និងការលើកកម្ពស់កិត្តិនាមទេសចរណ៍ និងការអភិវឌ្ឍទេសចរណ៍ ដោយ

ផ្តោតលើការជំរុញការអភិវឌ្ឍផលិតផល និងការពង្រឹងគុណភាពសេវាទេសចរណ៍ ព្រមទាំងការឃោសនាផ្សព្វផ្សាយ ដើម្បីទាក់ទាញផង និងជួយបង្កើនតម្លៃបន្ថែមរបស់វិស័យនេះផង,

- ការរៀបចំគោលនយោបាយអភិវឌ្ឍន៍វិស័យអាកាសចរណ៍ស៊ីវិល ការគ្រប់គ្រងប្រតិបត្តិការនិងសេវាកម្ម អាកាសចរណ៍ស៊ីវិល និងការកែលម្អសុវត្ថិភាព និងសន្តិសុខអាកាសចរណ៍ស៊ីវិល,
- ការបន្តពង្រឹងការផ្តល់សេវាសាធារណៈផ្នែកពាណិជ្ជកម្ម ដូចជា ការថែទាំប្រព័ន្ធស្វ័យប្រវត្តិកម្មបញ្ជាក់ប្រភពដើមទំនិញ ការគ្រប់គ្រងថែទុករក្សាទិន្នន័យក្រុមហ៊ុន-សហគ្រាស និងការស្វែងរកទីផ្សារ សម្រាប់ការនាំចេញរបស់កម្ពុជា ជាដើម,
- ការត្រួតពិនិត្យទំនិញ ការផ្តល់ព័ត៌មានដល់អ្នកប្រើប្រាស់ និងការត្រួតពិនិត្យបញ្ជាក់ទៅលើវិធានបទប្បញ្ញត្តិពាក់ព័ន្ធអនុវត្តច្បាប់កិច្ចការពារអ្នកប្រើប្រាស់,
- ការបន្តពង្រឹងការត្រួតពិនិត្យសុវត្ថិភាពចំណីអាហារ, និង
- ការគ្រប់គ្រង និងការអភិវឌ្ឍវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ពិសេសការលើកកម្ពស់គុណភាព ប្រសិទ្ធភាព សុវត្ថិភាព និងសន្តិសុខសាយប័រ ដើម្បីកសាងមូលដ្ឋានគ្រឹះ សម្រាប់ឈានទៅអនុវត្តសេដ្ឋកិច្ចឌីជីថលនៅកម្ពុជា។

ទន្ទឹមនេះ, រាជរដ្ឋាភិបាល បានត្រៀមបម្រុងថវិកា សម្រាប់អនុវត្តវិធានការចាំបាច់នានា សំដៅទ្រទ្រង់កំណើនតាមវិស័យគោលដៅ រក្សាលំនឹងជីវភាពប្រជាជន និង លើកកម្ពស់សមធម៌សង្គម ដូចខាងក្រោម ៖



### ៣.៣.២. ចំណាយមូលធនថវិកាថ្នាក់ជាតិ



ត្រូវបានគ្រោងចំនួន **១៣ ២១២ ប៊ីលានរៀល** មានសមាមាត្រស្មើនឹង **៣៤,៤%** នៃចំណាយសរុបថវិកាថ្នាក់ជាតិ ត្រូវជា **៦,០៩%** នៃ ផ.ស.ស. ឬកើនចំនួន **១៤,៩%** ធៀបនឹងច្បាប់-ហិរញ្ញវត្ថុឆ្នាំ ២០២៥ ដែលក្នុងនោះ **គម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេសនៅថ្នាក់ជាតិ** ត្រូវបានគ្រោងក្នុងទំហំប្រមាណ **២,៨៤%** នៃ ផ.ស.ស.។

គម្រោងចំណាយមូលធននេះ ត្រូវបានផ្តល់អាទិភាពលើ ៖

- ការអនុវត្តគម្រោងស្ថាបនាលើកកម្រិតគុណភាព និងជួសជុលស្តារឡើងវិញនូវហេដ្ឋា-រចនាសម្ព័ន្ធផ្លូវថ្នល់ រួមមាន ផ្លូវជាតិសំខាន់ៗ, ផ្លូវខេត្ត, ផ្លូវស្រុក, ផ្លូវជនបទ, ប្រព័ន្ធលូ និងហេដ្ឋារចនាសម្ព័ន្ធផ្លូវទឹក ដែលក្នុងនោះរួមមានការស្តារឡើងវិញផ្លូវទឹក និងសាងសង់កំពង់ផែ និង សំណង់សិល្បការ្យនានា
- ការបន្តអនុវត្តគម្រោងស្តារឡើងវិញ និងពង្រីកសក្តានុពលប្រព័ន្ធធារាសាស្ត្រ
- ការបន្តអនុវត្តគម្រោងសាងសង់ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់ អគារអធិការដ្ឋាននគរបាលក្រុងរុនតាឯក, អគារស្នាក់នៅ, ឃ្លាំង, ចំណតសម្រាប់ផ្ទេរទំនិញនៅច្រកទ្វារព្រំដែនអន្តរជាតិម៉ឺនជ័យ (កម្ពុជា-វៀតណាម) និង គម្រោងសាងសង់ និង ពង្រីកពន្ធនាគារនៅតាមបណ្តាខេត្តអាទិភាព
- ការបន្តកសាងហេដ្ឋារចនាសម្ព័ន្ធវិស័យសុខាភិបាល, វិស័យអប់រំ និង ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- ការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់ផលិតកម្មដំណាំសាកវប្បកម្ម, គម្រោងរៀបចំប្រព័ន្ធផ្គត់ផ្គង់ទឹកនៅឧទ្យានសត្វព្រៃ ភ្នំតាម៉ៅ និងគម្រោងគ្រប់គ្រង ការពារ និងអភិវឌ្ឍបម្ការព្ធជឈើគ្រញូង ខេត្តសៀមរាប
- ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត, តបណ្តាញប្រព័ន្ធទឹកស្អាត និងទិញឧបករណ៍បច្ចេកទេស សម្រាប់ពង្រឹងសមត្ថភាពមន្ទីរពិសោធន៍
- ការបន្តកសាងហេដ្ឋារចនាសម្ព័ន្ធផ្នែកប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន, មជ្ឈមណ្ឌលទិន្នន័យជាតិ និង ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត ជាដើម។

**ព័ត៌មានបន្ថែមសម្រាប់ទំហំចំណាយថវិកាសរុប ដែលរួមបញ្ចូលទាំងចំណាយចរន្ត និងចំណាយមូលធន (គម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស និងក្រៅប្រទេស) របស់ក្រសួង ស្ថាប័ន មានក្នុងតារាងឧបសម្ព័ន្ធ ៥.២។**

### ៣.៤. ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

គម្រោងចំណូល-ចំណាយរបស់រដ្ឋបាលរាជធានី-ខេត្ត, ក្រុង-ស្រុក, និង ឃុំ-សង្កាត់ ខាងលើ បានធ្វើឱ្យមានឱនភាពថវិកាចំនួន **១ ៨១៤,៩ ប៊ីលានរៀល**, ត្រូវជា **០,៨៤%** នៃ ផ.ស.ស., ដែលត្រូវបានគ្រោងឧបត្ថម្ភធនបំពេញតុល្យភាពដោយថវិកាថ្នាក់ជាតិ ក្នុងនោះ ៖ (១)-ឧបត្ថម្ភរាជធានី ខេត្ត (សម្រាប់រដ្ឋបាលខណ្ឌ) ចំនួន ១៣,១ ប៊ីលានរៀល; (២)-ឧបត្ថម្ភមូលនិធិក្រុង ស្រុក ចំនួន ៥៤៧,៧ ប៊ីលានរៀល; (៣)-ឧបត្ថម្ភមូលនិធិឃុំ សង្កាត់ ចំនួន ៩៧៥,៤ ប៊ីលានរៀល និង (៤)-មូលនិធិអភិវឌ្ឍឃុំ សង្កាត់ ចំនួន ២៧៨,៧ ប៊ីលានរៀល ដែលជាការផ្ទេរធនធានបន្ថែមពីលើមូលនិធិឃុំ សង្កាត់ ជូន រដ្ឋបាលឃុំ សង្កាត់ សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន។ ការឧបត្ថម្ភធនបន្ថែមនេះ នឹងធ្វើឱ្យរដ្ឋបាលឃុំ សង្កាត់ នីមួយៗទទួលបានថវិកាសរុបជាមធ្យមប្រមាណ ៨១៥ លានរៀល ឬសមមូលនឹង ២០១ ០០០ ដុល្លារអាម៉េរិក ក្នុងនោះ ថវិកាសម្រាប់ផ្នែកអភិវឌ្ឍន៍មូលដ្ឋានឃុំ សង្កាត់នីមួយៗ ទទួលបានជាមធ្យមប្រមាណ ៤១៥ លានរៀល ឬ សមមូលនឹង ១០២ ០០០ ដុល្លារអាម៉េរិក ក្នុង ១ ឆ្នាំ។

| ថវិកាថ្នាក់ក្រោមជាតិ (លានរៀល) | ២០២៥ | | ២០២៦ | | គ២៦/ ច្បា២៥ |
|---|---|---|---|---|---|
| | ច្បាប់ | % ផសស | ច្បាប់ | % ផសស | |
| **ចំណូលថវិកាថ្នាក់ក្រោមជាតិ** | **2.552.210** | **1,26%** | **2.460.486** | **1,13%** | **96,4%** |
| •ចំណូលសារពើពន្ធ | 2.218.739 | 1,10% | 1.987.570 | 0,92% | 89,6% |
| •ចំណូលមិនមែនសារពើពន្ធ | 300.735 | 0,15% | 417.014 | 0,19% | 138,7% |
| •ចំណូលផ្សេងៗ | 32.736 | 0,02% | 55.902 | 0,03% | 170,8% |
| **សរុបចំណាយថវិកាថ្នាក់ក្រោមជាតិ** | **4.421.580** | **2,19%** | **4.275.380** | **1,97%** | **96,7%** |
| •ចំណាយចរន្ត | 4.021.580 | 1,99% | 3.891.380 | 1,79% | 96,8% |
| •ចំណាយមូលធន | 400.000 | 0,20% | 384.000 | 0,18% | 96,0% |
| **ឱនភាពថវិកា** | **-1.869.370** | **-0,92%** | **-1.814.894** | **-0,84%** | **97,1%** |
| **ឧបត្ថម្ភដល់ថ្នាក់ក្រោមជាតិ** | **1.869.370** | **0,92%** | **1.814.894** | **0,84%** | **97,1%** |
| •រាជធានី-ខេត្ត (សម្រាប់រដ្ឋបាលខណ្ឌ) | 13.052 | 0,01% | 13.100 | 0,01% | 100,4% |
| •ក្រុង-ស្រុក | 558.676 | 0,28% | 547.671 | 0,25% | 98,0% |
| •ឃុំ-សង្កាត់ | 1.009.277 | 0,50% | 975.429 | 0,45% | 96,6% |
| •មូលនិធិអភិវឌ្ឍន៍ឃុំ-សង្កាត់ | 288.365 | 0,14% | 278.694 | 0,13% | 96,6% |

ជាមួយនឹងការបង្កើនចំណាយដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍន៍នៅរដ្ឋបាលថ្នាក់ក្រោមជាតិ, ក្នុងទំហំចំណាយចរន្តនេះប្រាក់បំណាច់របស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក៏ដូចជាក្រុមប្រឹក្សាឃុំ សង្កាត់ និងមន្ត្រីភូមិ សម្រាប់ឆ្នាំ ២០២៦ មានស្ថានភាព ដូចខាងក្រោម ៖

- **ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត** ទទួលបាន **១ ៦៨៥ ០០០ រៀល**,
- **សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត** ទទួលបាន **១ ២៨០ ០០០ រៀល**,
- **ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ** ទទួលបាន **១ ៣៩៥ ០០០ រៀល**,
- **សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ** ទទួលបាន **១ ០៥០ ០០០ រៀល**,
- **មេឃុំ ចៅសង្កាត់** ទទួលបាន **១ ៣៤៥ ០០០ រៀល**,
- **ជំទប់ទី១ ទី២ ចៅសង្កាត់រងទី១ ទី២** ទទួលបាន **១ ០០៥ ០០០ រៀល**,
- **សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់** ទទួលបាន **៨៩៥ ០០០ រៀល**,
- **មេភូមិ** ទទួលបាន **៥៧០ ០០០ រៀល**,
- **អនុប្រធានភូមិ** ទទួលបាន **៤៤៥ ០០០ រៀល**,
- **សមាជិកភូមិ** ទទួលបាន **៤១៥ ០០០ រៀល**។

លើសពីនេះទៀត គួរកត់សម្គាល់ថា ទំហំថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដូចជម្រាបជូនខាងលើ នៅមិនទាន់គិតបញ្ចូលនូវកញ្ចប់ថវិការបស់មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ដែលជាការប្រគល់មុខងារមានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត និងកញ្ចប់ថវិកានៃការប្រគល់មុខងារមានភ្ជាប់លក្ខខណ្ឌក្នុងវិស័យអប់រំរួមមានការិយាល័យអប់រំក្រុង ស្រុក ខណ្ឌ និងមុខងារចំនួន ៣ ផ្សេងទៀត ដែលរួមមាន៖ មុខងារគ្រប់គ្រងការអប់រំកុមារតូច មុខងារគ្រប់គ្រងការអប់រំបឋមសិក្សា និងមុខងារគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធ ទៅឱ្យគ្រប់រដ្ឋបាល ក្រុង ស្រុក ខណ្ឌទាំងអស់ទូទាំងប្រទេស។ ដូចនេះបើគិតបញ្ចូលទាំងកញ្ចប់ថវិកានៃការប្រគល់មុខងារមានភ្ជាប់លក្ខខណ្ឌនេះ ដែលត្រូវផ្ទេរជូនភ្លាម បន្ទាប់ពីច្បាប់ហិរញ្ញវត្ថុត្រូវបានអនុម័ត ក្នុងក្របខ័ណ្ឌនៃការអនុវត្តថវិកាកញ្ចប់ថវិកាចំណាយចរន្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនឹងមានទំហំសរុបស្មើនឹង ៦ ៦៨៦ ប៊ីលានរៀល មានសមាមាត្រស្មើនឹង ២៤,៥% នៃចំណាយចរន្តសរុបថវិការដ្ឋត្រូវជា ៣,០៨% នៃ ផ.ស.ស.។

### ៣.៥. ការកំណត់ពិតាននៃការខ្ចីសម្រាប់ឆ្នាំ ២០២៦

នៅឆ្នាំ ២០២៦ រាជរដ្ឋាភិបាល គ្រោងធ្វើការបោះផ្សាយមូលបត្ររដ្ឋចំនួន **២ ១១៤ ប៊ីលានរៀល សមមូលនឹងប្រមាណ ៥២៤ លានដុល្លារអាម៉េរិក** សម្រាប់ហិរញ្ញប្បទានលើចំណាយវិនិយោគ និងរក្សាតុល្យភាពថវិកាជាតិ។

ទន្ទឹមនេះ, រាជរដ្ឋាភិបាលកំណត់ទំហំនៃការខ្ចីប្រាក់ពីដៃគូអភិវឌ្ឍចំនួន ២,២៥ ប៊ីលានអេសដេអ៊ែ សមមូលនឹងប្រមាណ ៣,១ ប៊ីលានដុល្លារអាម៉េរិក កើនចំនួន ២៥០ លានអេសដេអ៊ែ ពីឆ្នាំ ២០២៥ ដោយផ្អែកលើទិដ្ឋភាព៖ (១)-ទំហំនៃតម្រូវការវិនិយោគសាធារណៈដែលកម្ពុជាមានភាពចាំបាច់ក្នុងការកៀរគរធនធានបន្ថែមឱ្យបានច្រើន ដើម្បីបំពេញតម្រូវការសម្រាប់ជំរុញកំណើនសេដ្ឋកិច្ច (២)-កម្មវិធី/គម្រោងអភិវឌ្ឍន៍ដែលត្រូវបានគ្រោងចុះកិច្ចព្រមព្រៀងឥណទានសម្បទានក្នុងឆ្នាំ ២០២៦ ជាកម្មវិធី/គម្រោងវិនិយោគសាធារណៈក្នុងវិស័យអាទិភាព (ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការបង្កើនផលិត-ភាពសេដ្ឋកិច្ច និងផលិតភាពផលិតកម្ម) ដែលមានចរិតយុទ្ធសាស្ត្រក្នុងការទ្រទ្រង់ដល់ចីរភាពនៃកំណើនសេដ្ឋកិច្ច ក្នុងរយៈពេលមធ្យម និងវែង, (៣)-ឥណទានមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះ (៤)-ស្ថានភាពបំណុលសាធារណៈកម្ពុជាបច្ចុប្បន្ន និងក្នុងរយៈពេលមធ្យមនៅតែមាន "**ចីរភាព**" និង "**ហានិភ័យកម្រិតទាប**" និង (៥)-ការបន្តបង្កើនប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រង និងអនុវត្តគម្រោង។

កម្មវិធី/គម្រោងអភិវឌ្ឍន៍សំខាន់ៗ ត្រូវបានបែងចែកតាមវិស័យដូចខាងក្រោម៖

- **វិស័យថាមពលចំនួន ៥ គម្រោង គឺ៖** គម្រោងប្រព័ន្ធអាគុយស្តុកថាមពល, គម្រោងជួសជុលបណ្តាញដោយមិនផ្តាច់ចរន្ត, គម្រោងពង្រីកសមត្ថភាពផ្គត់ផ្គង់អគ្គិសនី ជំហានទី ១, គម្រោងការផ្លាស់ប្តូរថាមពលប្រកបដោយនិរន្តរភាព, និងគម្រោងពង្រីកសមត្ថភាពផ្គត់ផ្គង់អគ្គិសនី ជំហានទី ២។
- **វិស័យទឹកស្អាតចំនួន ២ គម្រោង គឺ៖** គម្រោងអភិវឌ្ឍន៍ការផ្គត់ផ្គង់ទឹកស្អាតក្នុងក្រុងប្រកបដោយចីរភាព, និងគម្រោងអភិវឌ្ឍន៍ការផ្គត់ផ្គង់ទឹកស្អាតប្រកបដោយនិរន្តរភាព នៅក្នុងខេត្តបន្ទាយមានជ័យ ក្រោមកម្មវិធីវិនិយោគកែលម្អសេវាទីក្រុងដែលធន់នឹងអាកាសធាតុ។
- **វិស័យធារាសាស្ត្រចំនួន ៤ កម្មវិធី/គម្រោង គឺ៖** កម្មវិធីគ្រប់គ្រងធនធានទឹក និងការផ្លាស់ប្តូរវិស័យកសិកម្មសម្រាប់ប្រទេសកម្ពុជា ដំណាក់កាលទី ២, គម្រោងគ្រប់គ្រងទឹក ការស្រោចស្រព បង្ការទឹកជំនន់ និងការរាំងស្ងួតប្រកបដោយចីរភាព ជំហានទី ១, គម្រោងស្តារឡើងវិញនូវប្រព័ន្ធស្រោចស្រព

និងប្រព័ន្ធដោះទឹក ភាគនិរតីរាជធានីភ្នំពេញ (កញ្ចប់ឥណទានថ្មី), និង គម្រោងអភិវឌ្ឍន៍ធនធានទឹកស្ទឹងតាសាល ដំណាក់កាលទី ២។

- **វិស័យហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងដឹកជញ្ជូនចំនួន ១១ គម្រោង គឺ៖** គម្រោងកែលម្អបណ្តាញផ្លូវជាតិដែលធន់នឹងការប្រែប្រួលអាកាសធាតុ, គម្រោងជំរុញការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធច្រកទ្វារព្រំដែន, គម្រោងសាងសង់ផ្លូវជនបទបន្ទាន់, គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទីក្រុង, គម្រោងសាងសង់ផ្លូវជាតិលេខ ៥០C រួមទាំងស្ពានឆ្លងទន្លេសាប និងបូមស្ពានទន្លេសាប, គម្រោងបូមស្ពានទន្លេមេគង្គភាគខាងលើ, គម្រោងអភិវឌ្ឍន៍ស្ពានឆ្លងទន្លេមេគង្គ និងផ្លូវជាតិលេខ ១, គម្រោងការតភ្ជាប់ផ្លូវទៅស្ពានមិត្តភាពកម្ពុជា-សាធារណរដ្ឋកូរ៉េ, គម្រោងជំរុញការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ថ្នាក់តំបន់, គម្រោងលើកកម្រិត និងពង្រីកផ្លូវប្រាសាទ, គម្រោងអភិវឌ្ឍន៍ចំណតផែកុងតឺន័រថ្មី (ឥណទានសម្បទានបន្ថែម)។
- **វិស័យអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន ៣ កម្មវិធី/គម្រោង គឺ៖** កម្មវិធីបណ្តុះបណ្តាលជំនាញសម្រាប់តម្រូវការសេដ្ឋកិច្ចពេលអនាគត, កម្មវិធីបណ្តុះ-បណ្តាលជំនាញសម្រាប់តម្រូវការសេដ្ឋកិច្ចពេលអនាគត (ហិរញ្ញប្បទានបន្ថែម), គម្រោងអភិវឌ្ឍន៍គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈឯកទេស។
- **វិស័យសុខាភិបាលចំនួន ១ គម្រោង គឺ៖** គម្រោងហេដ្ឋារចនាសម្ព័ន្ធគាំទ្រភាពធន់នៃប្រព័ន្ធសុខាភិបាល។
- **វិស័យកសិកម្មចំនួន ១ គម្រោង គឺ៖** គម្រោងអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ចខ្នាតតូចប្រកបដោយភាពធន់។
- **វិស័យអាទិភាពផ្សេងទៀតចំនួន ២ កម្មវិធី/គម្រោង គឺ៖** កម្មវិធីអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម និងការប្រកួតប្រជែង អនុកម្មវិធីទី ៣, និង គម្រោងមូលនិធិអភិវឌ្ឍសហគ្រិនភាព។

គួរគូសបញ្ជាក់ថា ការបោះផ្សាយលក់មូលបត្ររដ្ឋ និងការខ្ចីពីក្រៅប្រទេសក្នុងទំហំខាងលើនេះ នឹងមិនបង្កើតជាបន្ទុកបំណុលវ័ណ្ឌកដល់កម្ពុជាទេ ពោលគឺជាទិដ្ឋភាពបច្ចេកទេស, ស្ថានភាពបំណុលសាធារណៈ កម្ពុជានៅតែត្រូវបានវាយតម្លៃថាមាន ចីរភាព និង ហានិភ័យកម្រិតទាបដដែល ដោយរាល់សូចនាករបំណុលគន្លឹះៗរបស់កម្ពុជាសុទ្ធតែស្ថិតក្រោមអនុបាតគោលទាំងអស់។

## ៣.៦. ស្ថានភាពបំណុល

<u>**សន្និធិបំណុលសាធារណៈគិតត្រឹមដំណាច់ឆ្នាំ ២០២៥ (ប៉ាន់ស្មាន)**</u>




តាមការប៉ាន់ស្មានគិតត្រឹមដំណាច់ឆ្នាំ ២០២៥, កម្ពុជាមានសន្និធិបំណុលសាធារណៈសរុបចំនួន **១៣ ០៩០ លានដុល្លារអាមេរិក** ស្មើនឹងប្រមាណ ២៦% នៃ ផ.ស.ស. (ជាតម្លៃចារឹក) ក្នុងនោះ៖

- ○ **សន្និធិបំណុលសាធារណៈក្នុងប្រទេស** មានចំនួន ***២៤៧ លានដុល្លារអាមេរិក***
- ○ **សន្និធិបំណុលសាធារណៈក្រៅប្រទេស** មានចំនួន ***១២ ៨៤៣ លានដុល្លារអាមេរិក***

<u>**សូចនាករចីរភាពបំណុល**</u>



<u>សូចនាករចីរភាពបំណុល</u>







តម្លៃចារឹក　តម្លៃបច្ចុប្បន្ន　សេវាបំណុល　អនុបាតគោល

# សូចនាករចីរភាពបំណុល







តម្លៃចារឹក តម្លៃបច្ចុប្បន្ន សេវាបំណុល អនុបាតគោល

## ជំពូក ៤. សេចក្តីសន្និដ្ឋាន



ក្របខ័ណ្ឌថវិកាឆ្នាំ ២០២៦ ត្រូវបានរៀបចំឡើងដោយប្រកាន់យកនូវ **«ដំហរគោលនយោបាយពង្រឹងសក្តិសិទ្ធិភាពថវិកា ដើម្បីទ្រទ្រង់ស្ថិរភាព និងកំណើន»** ក្នុងគោលដៅដោះស្រាយឱ្យបានជាសារវន្តនូវសេចក្តីត្រូវការ និងការឆ្លើយតបទៅនឹងអាទិភាពគោលនយោបាយធំៗរបស់រាជរដ្ឋាភិបាល និងតម្រូវការចាំបាច់ជាមូលដ្ឋានរបស់ក្រសួង ស្ថាប័ននានា ឆ្ពោះទៅសម្រេចគោលដៅសំខាន់ៗនៃកម្មវិធីនយោបាយ និង យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១ របស់រាជរដ្ឋាភិបាល ដែលជាមាគ៌ារយៈពេលមធ្យមមួយ ដើម្បីឈានទៅសម្រេចបាននូវបំណងប្រាថ្នារយៈពេលវែងរបស់ប្រជាជនកម្ពុជា ជារដ្ឋមួយរឹងមាំ មានអធិបតេយ្យជាតិ និងបូរណភាពទឹកដីពេញលេញ មានសន្តិភាព គោរពខ្ជាប់ខ្ជួននូវគោលការណ៍ប្រជាធិបតេយ្យនិងនីតិរដ្ឋ និងមានកិត្យានុភាពខ្ពស់ត្រដែតលើឆាកអន្តរជាតិ។ ក្របខ័ណ្ឌថវិកាខាងលើនេះ ក៏មានគោលដៅរក្សាឱ្យបានគង់វង្ស និងអភិវឌ្ឍន៍បន្ថែមទៀតនូវសមិទ្ធផលនៃការអភិវឌ្ឍទាំងពួងដែលសម្រេចបាននៅក្នុងនីតិកាលមុនៗកន្លងមក។

ដូចនេះ, ថវិកាឆ្នាំ ២០២៦ នឹងដើរតួនាទីជាឧបករណ៍គោលនយោបាយរបស់រាជរដ្ឋាភិបាលប្រកបដោយសក្តិសិទ្ធិភាព និងប្រសិទ្ធភាព ក្នុងការពង្រឹងសមត្ថភាពការពារអធិបតេយ្យជាតិ និងបូរណភាពទឹកដី ព្រមទាំងការពង្រឹងថែមទៀតនូវសមិទ្ធផលដ៏ធំធេងដែលកម្ពុជាសម្រេចបានកន្លងមក ក៏ដូចជា ក្នុងការបន្តបុកគ្រឹះសម្រាប់បម្រើឱ្យការអភិវឌ្ឍរបស់កម្ពុជាតទៅមុខទៀត។ អាទិភាពចំណាយថវិកាឆ្នាំ ២០២៦ គឺជាការឆ្លើយតបទៅនឹងអាទិភាព និងតម្រូវការចាំបាច់របស់ក្រសួង ស្ថាប័ននានា ជាពិសេស ការផ្សារភ្ជាប់សកម្មភាពអនុវត្តការងារ ទៅនឹងគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ន ក៏ដូចជាគោលនយោបាយជាអាទិភាពរួមរបស់រាជរដ្ឋាភិបាល ដែលរួមមាន : ការអភិវឌ្ឍមនុស្ស និងស្ថាប័ន ការកសាង ជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការធ្វើពិពិធកម្មសេដ្ឋកិច្ច ជាពិសេសការបង្កើតតម្លៃបន្ថែមក្នុងវិស័យចន្ទល់សេដ្ឋកិច្ចដែលមានស្រាប់ និងអនុវិស័យពាក់ព័ន្ធ ការជំរុញការវិនិយោគក្នុងវិស័យកសិកម្ម ការរៀបចំខ្លួនសម្រាប់ឈោងចាប់យកបច្ចេកវិទ្យាថ្មីៗក្នុងយុគសម័យសេដ្ឋកិច្ចឌីជីថល ការពង្រីកវិសាលភាព និងការពង្រឹងគុណភាពនៃសេវាសាធារណៈគ្រប់ប្រភេទ ជាពិសេសសេវាអប់រំ សេវាសុខាភិបាល សេវាយុត្តិធម៌ និងសេវាមូលដ្ឋានចាំបាច់ដទៃទៀត និងការកែទម្រង់អភិបាលកិច្ច ទាំងនៅថ្នាក់ជាតិ

និងថ្នាក់ក្រោមជាតិ ព្រមទាំងការអនុវត្តរបបគាំពារសង្គម ដោយឈរលើគោលការណ៍ប្រសិទ្ធភាព សមធម៌សង្គម ចីរភាព និងភាពអាចទ្រទ្រង់បាននៃថវិកា, ហើយត្រូវបានប្រសិទ្ធនាមថាជា "**ថវិកាដើម្បីពង្រឹងសមត្ថភាពការពារអធិបតេយ្យជាតិ និងបូរណភាពទឹកដី ធានាសុខសន្តិភាព រក្សាលំនឹងសង្គម-សេដ្ឋកិច្ច ធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច អភិវឌ្ឍន៍មនុស្សនិងស្ថាប័ន និងលើកកម្ពស់ភាពប្រកួតប្រជែង តាមរយៈការពង្រឹងសក្តិសិទ្ធិភាព និងការធានាចីរភាពហិរញ្ញវត្ថុសាធារណៈ សំដៅលើកកម្ពស់សុខដុមភាពសង្គម ទ្រទ្រង់កំណើនសេដ្ឋកិច្ច និងជំរុញការអភិវឌ្ឍឆ្ពោះទៅសម្រេចគោលដៅសំខាន់ៗនៃយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១**"។

# ជំពូក ៥. តារាងឧបសម្ព័ន្ធ

## ៥.១. ថវិកាកម្មវិធីរបស់ក្រសួង-ស្ថាប័ន តាមកម្មវិធី អនុកម្មវិធី (ឯកតា: លានរៀល)

| តារាង ១ ៖ គម្រោងចំណាយថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ ២០២៦ |
|---|---|
| **សរុបរួម** | **4.130.834,2** |
| **សរុបថវិកាឧបត្ថម្ភធនពីក្រសួង ដល់ រដ្ឋបាលក្រុង ស្រុក** | **1.858.417,7** |
| **សរុបថវិកាកម្មវិធី** | **2.272.416,5** |
| **កម្មវិធីទី១៖ ការអភិវឌ្ឍការអប់រំក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ** | **1.488.563,6** |
| អនុកម្មវិធីទី១៖ ការពង្រីកការអប់រំកុមារតូច | 16.263,2 |
| អនុកម្មវិធីទី២៖ ការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការអប់រំនៅបឋមសិក្សា | 7.917,8 |
| អនុកម្មវិធីទី៣៖ ការចូលរៀនប្រកបដោយសមធម៌ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅមធ្យមសិក្សា | 8.714,3 |
| អនុកម្មវិធីទី៤៖ ការពង្រីកការអប់រំក្រៅប្រព័ន្ធនិងបរិយាបន្ន | 4.649,5 |
| អនុកម្មវិធីទី៥៖ ការពង្រឹងនិងពង្រីកកម្មវិធីលើកកម្ពស់សុខភាពសិក្សា | 1.961,9 |
| អនុកម្មវិធីទី៦៖ លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីអប់រំបំប៉នបច្ចេកទេស | 4.691,8 |
| អនុកម្មវិធីទី៧៖ ការអភិវឌ្ឍការងារ បណ្តុះបណ្តាលគ្រូបង្រៀន | 3.095,3 |
| អនុកម្មវិធីទី៨៖ ការអភិវឌ្ឍកម្មវិធីសិក្សា សម្ភារៈសិក្សា និងបណ្ណាល័យ | 28.343,4 |
| អនុកម្មវិធីទី៩៖ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរបស់នាយកសាលា គ្រូបង្រៀន និងបុគ្គលិកអប់រំ | 2.198,3 |
| អនុកម្មវិធីទី១០៖ សេវាគាំទ្រការអភិវឌ្ឍការអប់រំក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការរបស់មន្ទីរជំនាញរាជធានី ខេត្ត | 1.410.728,1 |
| **កម្មវិធីទី២៖ ការអភិវឌ្ឍឧត្តមសិក្សា និងការស្រាវជ្រាវ** | **116.712,3** |
| អនុកម្មវិធីទី១៖ ការលើកកម្ពស់គុណភាពនិងភាពឆ្លើយតបនៃការអប់រំឧត្តមសិក្សា | 61.342,2 |
| អនុកម្មវិធីទី២៖ ការអភិវឌ្ឍការស្រាវជ្រាវនៅឧត្តមសិក្សា | 1.630,0 |
| អនុកម្មវិធីទី៣៖ ការពង្រឹងគុណភាពអប់រំ និងស្រាវជ្រាវប្រកបដោយប្រសិទ្ធភាព | 3.037,3 |
| អនុកម្មវិធីទី៤៖ ពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងការស្រាវជ្រាវប្រកបដោយប្រសិទ្ធភាព | 1.461,0 |
| អនុកម្មវិធីទី៥៖ លើកកម្ពស់គុណភាព នៃការបណ្តុះបណ្តាល និងការស្រាវជ្រាវ | 2.392,3 |
| អនុកម្មវិធីទី៦៖ ការអភិវឌ្ឍការបណ្តុះបណ្តាល និងស្រាវជ្រាវ | 6.580,7 |
| អនុកម្មវិធីទី៧៖ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងស្រាវជ្រាវ | 11.486,9 |
| អនុកម្មវិធីទី៨៖ ការលើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាល និងការស្រាវជ្រាវ | 3.374,0 |
| អនុកម្មវិធីទី៩៖ ពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងការស្រាវជ្រាវ | 1.458,6 |
| អនុកម្មវិធីទី១០៖ ការពង្រឹងគុណភាព ប្រសិទ្ធភាពអប់រំ និងស្រាវជ្រាវ | 3.041,9 |
| អនុកម្មវិធីទី១៣៖ ការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា | 759,0 |
| អនុកម្មវិធីទី១៤៖ ការពង្រឹងគុណភាព និងប្រសិទ្ធភាពការបណ្តុះបណ្តាល និងការស្រាវជ្រាវលើមុខជំនាញ STEAM | 2.768,6 |
| អនុកម្មវិធីទី១៥៖ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងស្រាវជ្រាវ | 1.573,0 |

| តារាង ១ ៖ គម្រោងចំណាយថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ ២០២៦ |
|---|---|
| **កម្មវិធីទី៣៖ ការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា** | **82.360,9** |
| អនុកម្មវិធីទី១៖ ការអភិវឌ្ឍកីឡាមហាជន | 6.389,5 |
| អនុកម្មវិធីទី២៖ ការអភិវឌ្ឍអប់រំកាយ និងកីឡាសិស្ស-និស្សិត | 2.973,0 |
| អនុកម្មវិធីទី៣៖ ការបណ្តុះបណ្តាលធនធានមនុស្សផ្នែកអប់រំកាយ និងកីឡា | 1.704,9 |
| អនុកម្មវិធីទី៤៖ ការអភិវឌ្ឍកីឡាកម្រិតខ្ពស់ | 22.766,6 |
| អនុកម្មវិធីទី៥៖ អភិវឌ្ឍការរៀបចំព្រឹត្តិការណ៍កីឡាគ្រប់កម្រិត និងចងក្រងស្ថិតិកីឡា | 16.895,1 |
| អនុកម្មវិធីទី៧៖ ពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងពហុកីឡដ្ឋានជាតិ | 9.365,1 |
| អនុកម្មវិធីទី៨៖ សេវាគាំទ្រការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡារបស់មន្ទីរជំនាញរាជធានី ខេត្ត | 22.266,7 |
| **កម្មវិធីទី៤៖ ការអភិវឌ្ឍយុវជន** | **22.766,6** |
| អនុកម្មវិធីទី១៖ ការអភិវឌ្ឍសកម្មភាពយុវជន | 7.574,5 |
| អនុកម្មវិធីទី២៖ ការអភិវឌ្ឍមជ្ឈមណ្ឌលយុវជន | 5.217,3 |
| អនុកម្មវិធីទី៣៖ ការអភិវឌ្ឍកាយរឹទ្ធិកម្ម | 1.197,8 |
| អនុកម្មវិធីទី៤៖ សេវាគាំទ្រការអភិវឌ្ឍយុវជនរបស់មន្ទីរជំនាញរាជធានី ខេត្ត | 8.777,0 |
| **កម្មវិធីទី៥៖ ការគាំទ្រសេវាអប់រំ និងអភិបាលកិច្ចល្អ** | **562.013,1** |
| អនុកម្មវិធីទី១៖ ការអភិវឌ្ឍ និងពង្រឹងប្រព័ន្ធផែនការអប់រំ | 1.262,0 |
| អនុកម្មវិធីទី២៖ ការគ្រប់គ្រង និងពង្រឹងប្រសិទ្ធភាពធនធានមនុស្ស | 55.802,9 |
| អនុកម្មវិធីទី៣៖ ការគ្រប់គ្រងហិរញ្ញវត្ថុ ការអភិវឌ្ឍសមត្ថភាព ការគាំទ្រការលើកកម្ពស់គុណភាពអប់រំ និងមូលដ្ឋានសម្ភារៈ | 309.825,6 |
| អនុកម្មវិធីទី៤៖ ការពង្រឹងការងារសវនកម្មផ្ទៃក្នុង | 513,9 |
| អនុកម្មវិធីទី៥៖ ការពិនិត្យតាមដាន វាយតម្លៃ និងអធិការកិច្ចប្រព័ន្ធធានាគុណភាពអប់រំ | 2.759,6 |
| អនុកម្មវិធីទី៦៖ អធិការកិច្ចរដ្ឋបាល និងហិរញ្ញវត្ថុ | 368,4 |
| អនុកម្មវិធីទី៧៖ លើកកម្ពស់និងអភិវឌ្ឍកិច្ចសហប្រតិបត្តិការជាតិ-អន្តរជាតិលើវិស័យអប់រំ | 8.733,6 |
| អនុកម្មវិធីទី៨៖ ការពង្រឹងការងារនីតិកម្ម | 646,0 |
| អនុកម្មវិធីទី៩៖ ការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធអប់រំ | 9.613,3 |
| អនុកម្មវិធីទី១១៖ ការអភិវឌ្ឍ និងពង្រឹងប្រសិទ្ធភាពការគ្រប់គ្រង និងការធានាភាពស័ក្តិសិទ្ធនៃសេវារដ្ឋបាល | 2.063,7 |
| អនុកម្មវិធីទី១៣៖ ការអភិវឌ្ឍប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ | 749,2 |
| អនុកម្មវិធីទី១៤៖ ការស្រាវជ្រាវ និងអភិវឌ្ឍគោលនយោបាយអប់រំ | 885,9 |
| អនុកម្មវិធីទី១៥៖ ការអភិវឌ្ឍនិងពង្រឹងប្រព័ន្ធពិនិត្យ តាមដាន និងវាយតម្លៃ | 718,0 |
| អនុកម្មវិធីទី១៦៖ ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានសម្រាប់ការងារអប់រំ យុវជន និងកីឡា | 731,5 |
| អនុកម្មវិធីទី១៨៖ សេវាគាំទ្រសេវាអប់រំ និងអភិបាលកិច្ចល្អ របស់មន្ទីរជំនាញរាជធានី ខេត្ត | 167.339,5 |

| តារាង ២៖ គម្រោងចំណាយថវិការបស់ក្រសួងសុខាភិបាល<br>តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ ២០២៦ |
|---|---|
| **សរុបរួម** | **2.315.333,0** |
| **សរុបរដ្ឋបាលកណ្តាល** | **1.379.407,0** |
| **សរុបមន្ទីរជំនាញរាជធានី ខេត្ត** | **935.926,0** |
| **កម្មវិធីទី ១ ៖ សុខភាពបន្តពូជ យុវវ័យ មាតា ទារក កុមារ និងអាហារូបត្ថម្ភ** | **147.644,4** |
| អនុកម្មវិធីទី ១ ៖ អាហារូបត្ថម្ភ | 1.620,9 |
| អនុកម្មវិធីទី២ ៖ សុខភាពបន្តពូជ | 9.788,4 |
| អនុកម្មវិធីទី៣ ៖ សុខភាពមាតា និងទារក | 27.436,0 |
| អនុកម្មវិធីទី៤ ៖ សុខភាពកុមារ | 108.799,1 |
| **កម្មវិធីទី២ ៖ ប្រយុទ្ធជំងឺឆ្លង និងការឆ្លើយតបនឹងគ្រោះអាសន្នសុខភាពសាធារណៈ** | **43.919,6** |
| អនុកម្មវិធីទី១ ៖ បង្ការ និងថែទាំព្យាបាលជំងឺអេដស៍ | 22.296,9 |
| អនុកម្មវិធីទី២ ៖ បង្ការ និងថែទាំព្យាបាលជំងឺរបេង | 9.571,7 |
| អនុកម្មវិធីទី៣ ៖ បង្ការ និងថែទាំព្យាបាលជំងឺគ្រុនចាញ់ និងគ្រុនឈាម | 1.286,9 |
| អនុកម្មវិធីទី៤ ៖ បង្ការ និងឆ្លើយតបជំងឺឆ្លងដទៃទៀត | 10.764,1 |
| **កម្មវិធីទី៣ ៖ ប្រយុទ្ធជំងឺមិនឆ្លង និងបញ្ហាសុខភាពសាធារណៈដទៃទៀត** | **78.915,2** |
| អនុកម្មវិធីទី២ ៖ សុខភាពផ្លូវចិត្ត និងបំពានគ្រឿងញៀន | 449,0 |
| អនុកម្មវិធីទី ៣ ៖ សុខភាពមាត់-ធ្មេញ | 113,0 |
| អនុកម្មវិធីទី៤ ៖ ជំងឺរ៉ាំរ៉ៃ | 75.795,6 |
| អនុកម្មវិធីទី៥ ៖ បញ្ហាសុខភាពសាធារណៈផ្សេងៗទៀត | 2.557,6 |
| **កម្មវិធីទី៤ ៖ ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ** | **1.108.927,8** |
| អនុកម្មវិធីទី១ ៖ ការផ្តល់សេវាសុខាភិបាល | 954.518,0 |
| អនុកម្មវិធីទី២ ៖ ហិរញ្ញប្បទានសុខាភិបាល | 54,9 |
| អនុកម្មវិធីទី៣ ៖ អភិវឌ្ឍន៍ធនធានមនុស្ស | 137.210,2 |
| អនុកម្មវិធីទី៤ ៖ ប្រព័ន្ធព័ត៌មានសុខាភិបាល | 69,0 |
| អនុកម្មវិធីទី៥ ៖ អភិបាលកិច្ចវិស័យសុខាភិបាល | 2.129,7 |
| អនុកម្មវិធីទី៦ ៖ សេវាគាំទ្រការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅសម្រាប់សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ | 14.946,0 |

| តារាង ៣៖ គម្រោងចំណាយថវិការបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ ២០២៦ |
|---|---|
| **សរុបរួម** | **2.574.398,0** |
| **កម្មវិធីទី ១ ៖ ការលើកកម្ពស់សេវាសង្គមកិច្ច** | **35.625,5** |
| អនុកម្មវិធីទី ១ ៖ លើកកម្ពស់សេវាគាំពារមនុស្សចាស់និងអតីតយុទ្ធជន | 4.768,0 |
| អនុកម្មវិធីទី ២ ៖ លើកកម្ពស់សេវាកិច្ចការពារកុមារ | 1.135,5 |
| អនុកម្មវិធីទី ៣ ៖ លើកកម្ពស់កិច្ចការគ្រួសារ | 221,2 |
| អនុកម្មវិធីទី ៤ ៖ លើកកម្ពស់សេវាគាំពារជនរងគ្រោះ | 13.989,2 |
| អនុកម្មវិធីទី ៥ ៖ សេវាគាំទ្រកាលើកកម្ពស់សេវាសង្គមកិច្ចតាមរាជធានី ខេត្ត | 15.511,6 |
| **កម្មវិធីទី ២ ៖ ការគ្រប់គ្រងសេវាស្តារជនរងគ្រោះ** | **34.335,3** |
| អនុកម្មវិធីទី ១ ៖លើកកម្ពស់សេវាស្តារនីតិសម្បទាអនីតិជន | 1.562,0 |
| អនុកម្មវិធីទី ២ ៖ លើកកម្ពស់សេវាស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន | 5.312,0 |
| អនុកម្មវិធីទី ៣ ៖ លើកកម្ពស់សុខុមាលភាពជនមានពិការភាព | 796,5 |
| អនុកម្មវិធីទី ៤ ៖ កៀរគរ និងប្រើប្រាស់មូលនិធិសង្គមកិច្ច | 259,3 |
| អនុកម្មវិធីទី ៥ ៖ លើកកម្ពស់សេវាស្តារលទ្ធភាពពលកម្មជូនជនមានពិការភាព (មជព) | 16.237,6 |
| អនុកម្មវិធីទី ៦ ៖ សេវាគាំទ្រការគ្រប់គ្រងសេវាស្តារជនរងគ្រោះតាមរាជធានី ខេត្ត | 10.167,9 |
| **កម្មវិធីទី ៣ ៖ សេវាគាំទ្រការអនុវត្តកម្មវិធីគាំពារសង្គម (មជជ)** | **2.443.837,1** |
| អនុកម្មវិធីទី ១ ៖ លើកកម្ពស់សេវាបើកផ្តល់តាវកាលិកនិងរបបគោលនយោបាយ | 2.414.158,8 |
| អនុកម្មវិធីទី ២ ៖ លើកកម្ពស់សមត្ថភាពស្ថាប័ន និងការផ្សព្វផ្សាយ | 1.026,5 |
| អនុកម្មវិធីទី ៣ ៖ រៀបចំគោលនយោបាយ និងកិច្ចការនីតិកម្មជំនួយសង្គម | 378,0 |
| អនុកម្មវិធីទី ៤ ៖ សេវាគាំទ្រកិច្ចដំណើរការអនុវត្តកម្មវិធីគាំពារសង្គម | 28.273,8 |
| **កម្មវិធីទី ៤ ៖ ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ** | **60.600,1** |
| អនុកម្មវិធីទី ១ ៖ លើកកម្ពស់សមត្ថភាពស្ថាប័ន និងអភិបាលកិច្ច | 31.438,9 |
| អនុកម្មវិធីទី ២ ៖ អភិវឌ្ឍន៍ធនធានមនុស្សវិស័យសង្គមកិច្ច (NISA) | 475,2 |
| អនុកម្មវិធីទី ៣ ៖ លើកកម្ពស់ការអភិវឌ្ឍគោលនយោបាយសង្គមកិច្ច | 518,5 |
| អនុកម្មវិធីទី ៤ ៖ លើកកម្ពស់ការត្រួតពិនិត្យតាមដានការអនុវត្តសិទ្ធិកុមារ (ក.ជ.ក CNCC) | 215,0 |
| អនុកម្មវិធីទី ៥ ៖ លើកកម្ពស់ការត្រួតពិនិត្យតាមដានការអនុវត្តសិទ្ធិជនពិការ (ក.ស.ជ DAC) | 285,0 |
| អនុកម្មវិធីទី ៦ ៖ ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅតាមរាជធានី-ខេត្ត | 27.667,5 |

| តារាង ៤៖ គម្រោងចំណាយថវិការបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ ២០២៦ |
|---|---|
| **សរុបរួម** | **469.850,3** |
| **កម្មវិធីទី១៖ គោលនយោបាយទីផ្សារការងារសកម្ម និងការគ្រប់គ្រងទេសន្តរប្រវេសន៍ការងារ** | **7.395,9** |
| អនុកម្មវិធីទី១.១៖ ការពង្រឹងការអនុវត្តគោលនយោបាយ និងសិក្សាស្រាវជ្រាវ | 350,0 |
| អនុកម្មវិធីទី១.២៖ ការពង្រឹងប្រសិទ្ធភាពនៃយន្តការផ្តល់សេវាការងារ | 4.965,4 |
| អនុកម្មវិធីទី១.៣៖ ការពង្រឹង និងពង្រីកសេវាប្រឹក្សាយោបល់ និងមគ្គុទេសក៍អាជីព ការងារ និងវិជ្ជាជីវៈ | 812,0 |

| តារាង ៤៖ គម្រោងចំណាយថវិការបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ ២០២៦ |
|---|---|
| អនុកម្មវិធីទី១.៤៖ ការពង្រឹងយន្តការគ្រប់គ្រងការប្រើប្រាស់កម្លាំងពលកម្មក្នុងប្រទេស តាមរយៈប្រព័ន្ធឌីជីថល | 103,4 |
| អនុកម្មវិធីទី១.៥៖ ការពង្រឹងការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ និងផលិតភាពការងារ | 685,1 |
| អនុកម្មវិធីទី១.៦៖ ការពង្រឹងការគ្រប់គ្រងទេសន្តរប្រវេសន៍ការងារ | 480,0 |
| **កម្មវិធីទី២៖ ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ** | **285.867,0** |
| អនុកម្មវិធីទី២.១៖ ការពង្រឹងប្រព័ន្ធអភិបាលកិច្ចវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | 60.286,2 |
| អនុកម្មវិធីទី២.២៖ ការធានាគុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | 67.222,0 |
| អនុកម្មវិធីទី២.៣៖ ការពង្រឹង និងពង្រីកការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | 155.031,6 |
| អនុកម្មវិធីទី២.៤៖ ការពង្រឹងភាពជាដៃគូរវាងរដ្ឋ ឯកជន និងដៃគូអភិវឌ្ឍន៍ | 605,1 |
| អនុកម្មវិធីទី២.៥៖ ការជំរុញការស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យាអនុវត្តន៍ | 690,0 |
| អនុកម្មវិធីទី៦៖ សេវាគាំទ្រការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ របស់មន្ទីរជំនាញរាជធានី-ខេត្ត | 2.032,1 |
| **កម្មវិធីទី៣៖ ការអភិវឌ្ឍលក្ខខណ្ឌការងារ សុវត្ថិភាពនិងសុខភាពការងារ និងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ** | **44.557,9** |
| អនុកម្មវិធីទី៣.១៖ ការពង្រឹងសមត្ថភាពអធិការការងារ និងយន្តការអធិការកិច្ចការងារ | 8.155,5 |
| អនុកម្មវិធីទី៣.៣៖ ការលុបបំបាត់ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ | 1.222,5 |
| អនុកម្មវិធីទី៣.៤៖ ការកំណត់ប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍របស់កម្មករនិយោជិត | 1.500,0 |
| អនុកម្មវិធីទី៣.៥៖ ការលើកកម្ពស់សុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ | 26.985,8 |
| អនុកម្មវិធីទី៣.៦៖ សេវាគាំទ្រលក្ខខណ្ឌការងារ សុវត្ថិភាពនិងសុខភាពការងារ និងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ របស់មន្ទីរជំនាញរាជធានី-ខេត្ត | 6.694,1 |
| **កម្មវិធីទី៤៖ ការអភិវឌ្ឍរបបសន្តិសុខសង្គម** | **7.529,6** |
| អនុកម្មវិធីទី៤.៥៖ ការអភិវឌ្ឍសមត្ថភាពបេឡាជាតិសន្តិសុខសង្គម | 7.529,6 |
| **កម្មវិធីទី៥៖ ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ** | **124.499,9** |
| អនុកម្មវិធីទី៥.១៖ ការពង្រឹងការគ្រប់គ្រងរដ្ឋបាល និងបុគ្គលិក | 36.909,5 |
| អនុកម្មវិធីទី៥.២៖ ការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុ និងធនធាន | 50.368,2 |
| អនុកម្មវិធីទី៥.៣៖ ការអភិវឌ្ឍសមត្ថភាពមន្ត្រី និងកសាងលិខិតបទដ្ឋានគតិយុត្ត | 2.759,6 |
| អនុកម្មវិធីទី៥.៤៖ ការពង្រឹងភាពជាម្ចាស់ក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិ សមភាពយេនឌ័រ និងសេវាសង្គម | 8.222,8 |
| អនុកម្មវិធីទី៥.៥៖ ការតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្រ | 175,1 |
| អនុកម្មវិធីទី៥.៦៖ ការគ្រប់គ្រង និងសេវាគាំទ្រទូទៅរបស់មន្ទីរជំនាញរាជធានី-ខេត្ត | 26.064,7 |

| តារាង ៥៖ គម្រោងចំណាយថវិការបស់ក្រសួងការពារជាតិ<br>តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ ២០២៦ |
|---|---|
| **សរុបរួម** | **2.999.597,0** |
| **កម្មវិធីទី១: ការដឹកនាំបញ្ជា ហ៊ីកហ៊ឺន ធ្វើប្រតិបត្តិការ ការពារសុខសន្តិភាព និងរក្សាសណ្ដាប់ធ្នាប់សង្គម** | **15.869,5** |
| អនុកម្មវិធីទី១: ដឹកនាំបញ្ជាតាមជំនាញ | 2.672,0 |
| អនុកម្មវិធីទី២: ប្រតិបត្តិការកងទ័ពជើងគោក | 3.365,0 |
| អនុកម្មវិធីទី៣: ប្រតិបត្តិការកងទ័ពជើងទឹក | 5.907,5 |
| អនុកម្មវិធីទី៤: ប្រតិបត្តិការកងទ័ពជើងអាកាស | 2.874,0 |
| អនុកម្មវិធីទី៥: ប្រតិបត្តិការកងរាជអាវុធហត្ថ | 792,0 |
| អនុកម្មវិធីទី៦: កិច្ចការពារសុវត្ថិភាពថ្នាក់ដឹកនាំ | 259,0 |
| **កម្មវិធីទី២: កិច្ចសហប្រតិបត្តិការយោធាក្នុងតំបន់ និងអន្តរជាតិ** | **13.568,5** |
| អនុកម្មវិធីទី១: ការងារការទូត និងនយោបាយវិស័យយោធា | 4.806,0 |
| អនុកម្មវិធីទី២: ប្រតិបត្តិការស្រាវជ្រាវ-ចារកិច្ច | 3.924,5 |
| អនុកម្មវិធីទី៣: ប្រតិបត្តិការរក្សាសន្តិភាពក្រោមឆ័ត្រអង្គការសហប្រជាជាតិ | 1.711,5 |
| អនុកម្មវិធីទី៤: ទប់ស្កាត់អាវុធ និងសារធាតុគីមីសង្គ្រាម | 3.126,5 |
| **កម្មវិធីទី៣: ការគ្រប់គ្រង និងថែទាំយុទ្ធោបករណ៍ និងសម្ភារៈបច្ចេកទេស** | **40.308,5** |
| អនុកម្មវិធីទី១: គ្រប់គ្រងថែទាំគ្រឿងបំពាក់បច្ចេកទេស | 12.240,5 |
| អនុកម្មវិធីទី២: សេវាគ្រប់គ្រង និងថែទាំជំនាញវិស្វកម្ម | 27.289,5 |
| អនុកម្មវិធីទី៣: សេវាគ្រប់គ្រង និងថែទាំជំនាញបញ្ជូនសារ | 778,5 |
| **កម្មវិធីទី៤: ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ** | **2.929.850,5** |
| អនុកម្មវិធី១: សេវារដ្ឋបាលទូទៅ | 2.518,5 |
| អនុកម្មវិធីទី២: ពង្រឹងគោលនយោបាយយោធសេវា | 35.622,0 |
| អនុកម្មវិធីទី៣: សេវាភស្តុភារហិរញ្ញវត្ថុ | 2.891.710,0 |

| តារាង ៦៖ គម្រោងចំណាយថវិការបស់ក្រសួងបរិស្ថាន<br>តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ ២០២៦ |
|---|---|
| **សរុបរួម** | **106.098,0** |
| **កម្មវិធីទី១៖ កិច្ចគាំពារបរិស្ថាន** | **14.608,5** |
| អនុកម្មវិធីទី១៖ ការតាមដានត្រួតពិនិត្យគុណភាពបរិស្ថាន (ទឹក-ដី-ខ្យល់) និងការគ្រប់គ្រងទឹកកខ្វក់ សំរាម សំណល់រឹងទីប្រជុំជន | 129,8 |
| អនុកម្មវិធីទី២៖ ការត្រួតពិនិត្យ និងអធិការកិច្ចប្រភពបំពុលបរិស្ថាន | 82,0 |
| អនុកម្មវិធីទី៣៖ សេវាគាំទ្រកិច្ចគាំពារបរិស្ថាន | 11.384,2 |
| អនុកម្មវិធីទី ៤ ៖ សេវាគាំទ្រកិច្ចគាំពារបរិស្ថាន របស់មន្ទីរបរិស្ថាន | 3.012,5 |
| **កម្មវិធីទី២ ៖ ការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ និងការអភិវឌ្ឍសហគមន៍មូលដ្ឋាន** | **34.382,2** |
| អនុកម្មវិធីទី១៖ គ្រប់គ្រង និងអភិរក្សតំបន់ការពារធម្មជាតិ | 1.174,9 |
| អនុកម្មវិធីទី២៖ សេវាគាំទ្រការងារគ្រប់គ្រង និងពង្រឹងការអនុវត្តច្បាប់ | 5.882,1 |

| តារាង ៦៖ គម្រោងចំណាយថវិការបស់ក្រសួងបរិស្ថាន តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ ២០២៦ |
|---|---|
| អនុកម្មវិធីទី៣៖ សេវាគាំទ្រការងារសហគមន៍មូលដ្ឋាន | 2.498,2 |
| អនុកម្មវិធីទី៤៖ អភិរក្សបេតិកភណ្ឌធម្មជាតិ-វប្បធម៌ | 260,4 |
| អនុកម្មវិធីទី៥៖ អភិវឌ្ឍទេសចរណ៍ធម្មជាតិ និងសហគមន៍មូលដ្ឋាន | 1.244,4 |
| អនុកម្មវិធីទី ៦ ៖ សេវាគាំទ្រការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ និង ការអភិវឌ្ឍសហគមន៍មូលដ្ឋាន របស់មន្ទីរបរិស្ថាន | 23.322,2 |
| **កម្មវិធីទី៣ ៖ ការរៀបចំគោលនយោបាយ និងការអភិវឌ្ឍដោយចីរភាព** | **3.900,2** |
| អនុកម្មវិធីទី១៖ អភិវឌ្ឍសេដ្ឋកិច្ចបៃតង និងការលើកកម្ពស់ការអនុវត្តវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា | 3.276,2 |
| អនុកម្មវិធីទី២៖ ជំរុញការអនុវត្តឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ | 146,1 |
| អនុកម្មវិធីទី ៣ ៖ អភិរក្សជីវៈចម្រុះ និងជីវសុវត្ថិភាព | 266,7 |
| អនុកម្មវិធីទី ៤ ៖ សេវាគាំទ្រការរៀបចំគោលនយោបាយ និងការអភិវឌ្ឍដោយចីរភាពរបស់មន្ទីរបរិស្ថាន | 211,2 |
| **កម្មវិធីទី៤ ៖ ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ** | **53.207,1** |
| អនុកម្មវិធីទី១៖ ផ្សព្វផ្សាយបរិស្ថាន | 3.941,2 |
| អនុកម្មវិធីទី២៖ វាយតម្លៃហេតុប៉ះពាល់បរិស្ថាន | 122,9 |
| អនុកម្មវិធីទី៣៖ គ្រប់គ្រងការងាររដ្ឋបាល និងខុទ្ទកាល័យ | 401,8 |
| អនុកម្មវិធីទី៤៖ គ្រប់គ្រង និងបណ្តុះបណ្តាលធនធានមនុស្ស | 10.011,6 |
| អនុកម្មវិធីទី៥៖ គ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ | 14.985,6 |
| អនុកម្មវិធីទី៦៖ រៀបចំផែនការ និងលើកកម្ពស់ការងារសង្គមក្នុងវិស័យបរិស្ថាន | 233,1 |
| អនុកម្មវិធីទី៧៖ ពង្រឹងអធិការកិច្ច និងសវនកម្មផ្ទៃក្នុង | 164,8 |
| អនុកម្មវិធីទី ៨ ៖ សេវាគាំទ្រការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ របស់មន្ទីរបរិស្ថាន | 23.346,1 |

| តារាង ៧៖ គម្រោងចំណាយថវិការបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ ២០២៦ |
|---|---|
| **សរុបរួម** | **190.750,5** |
| **កម្មវិធីទី ១ ៖ កិច្ចគាំពារបេតិកភណ្ឌវប្បធម៌រូបី** | **97.014,7** |
| អនុកម្មវិធីទី ១ ៖ ការបង្កើនកិច្ចអភិរក្សបេតិកភណ្ឌវប្បធម៌រូបី | 599,0 |
| អនុកម្មវិធីទី ២ ៖ ការលើកតម្កើងតម្លៃបេតិកភណ្ឌវប្បធម៌រូបី | 16.565,3 |
| អនុកម្មវិធីទី ៣៖ កិច្ចគាំពារនិងលើកតម្កើងតម្លៃបេតិកភណ្ឌវប្បធម៌ តំបន់រមណីយដ្ឋានអង្គរ | 61.678,0 |
| អនុកម្មវិធីទី ៤ ៖ កិច្ចគាំពារនិងលើកតម្កើងតម្លៃបេតិកភណ្ឌវប្បធម៌តំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ និងប្រាសាទកោះកេរ | 8.233,3 |
| អនុកម្មវិធីទី ៥ ៖កិច្ចគាំពារនិងលើកតម្កើងតម្លៃបេតិកភណ្ឌវប្បធម៌តំបន់រមណីយដ្ឋាន ប្រាសាទសំបូរព្រៃគុក | 4.418,2 |
| អនុកម្មវិធីទី ៦ ៖ សេវាគាំទ្រកិច្ចគាំពារបេតិកភណ្ឌវប្បធម៌រូបី ថ្នាក់រាជធានី ខេត្ត | 5.520,9 |

| តារាង ៧៖ គម្រោងចំណាយថវិការបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ ២០២៦ |
|---|---|
| **កម្មវិធីទី២ ៖ ការលើកស្ទួយបេតិកភណ្ឌវប្បធម៌អរូបី** | **22.266,2** |
| អនុកម្មវិធីទី ១ ៖ ការពង្រឹងកិច្ចអភិរក្សបេតិកភណ្ឌវប្បធម៌អរូបី | 2.456,0 |
| អនុកម្មវិធីទី ២ ៖ ការលើកតម្លៃបេតិកភណ្ឌវប្បធម៌អរូបី | 11.746,4 |
| អនុកម្មវិធីទី ៣ ៖ សេវាគាំទ្រការលើកស្ទួយបេតិកភណ្ឌវប្បធម៌អរូបី ថ្នាក់រាជធានី ខេត្ត | 8.063,8 |
| **កម្មវិធីទី ៣ ៖ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ** | **71.469,6** |
| អនុកម្មវិធីទី ១ ៖ ការពង្រឹងសមត្ថភាពនិងប្រសិទ្ធភាពការងាររបស់អង្គភាព | 41.927,2 |
| អនុកម្មវិធីទី ២ ៖ ការបណ្តុះបណ្តាលធនធានមនុស្សលើវិស័យវប្បធម៌កម្រិតមធ្យម | 2.880,0 |
| អនុកម្មវិធីទី ៣ ៖ ការបណ្តុះបណ្តាលធនធានមនុស្សលើវិស័យវប្បធម៌ កម្រិតឧត្តម | 3.900,7 |
| អនុកម្មវិធីទី ៤ ៖ ការពង្រឹងយន្តការការងាររបស់គណៈកម្មាធិការជាតិបេតិកភណ្ឌពិភពលោក | 385,0 |
| អនុកម្មវិធីទី ៥ ៖ ការពង្រឹងយន្តការការងាររបស់គណៈកម្មការជាតិយូណេស្កូកម្ពុជា | 395,0 |
| អនុកម្មវិធីទី ៦ ៖ សេវាគាំទ្រ ការគ្រប់គ្រងស្ថាប័ន និងកិច្ចការរដ្ឋបាលទូទៅ ថ្នាក់រាជធានី ខេត្ត | 21.981,7 |

| តារាង ៨៖ គម្រោងចំណាយថវិការបស់ក្រសួងព័ត៌មាន តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ ២០២៦ |
|---|---|
| **សរុបរួម** | **89.035,2** |
| **កម្មវិធីទី ១ ៖ ការគ្រប់គ្រង និងអភិវឌ្ឍវិស័យព័ត៌មាន** | **89.035,2** |
| អនុកម្មវិធីទី ១ ៖ កិច្ចការព័ត៌មាន និងសោតទស្សន៍ | 1.137,2 |
| អនុកម្មវិធីទី ២ ៖ ការងារផ្សព្វផ្សាយរបស់ទូរទស្សន៍ជាតិកម្ពុជា | 3.648,2 |
| អនុកម្មវិធីទី ៣ ៖ ការងារផ្សព្វផ្សាយរបស់វិទ្យុជាតិកម្ពុជា | 1.178,7 |
| អនុកម្មវិធីទី ៤ ៖ ការងារផ្សព្វផ្សាយរបស់ទីភ្នាក់ងារសារព័ត៌មានកម្ពុជា AKP | 1.205,6 |
| អនុកម្មវិធីទី ៥ ៖ កិច្ចការរដ្ឋបាលទូទៅ | 51.403,3 |
| អនុកម្មវិធីទី ៦ ៖ សេវាគាំទ្រវិស័យព័ត៌មានរបស់មន្ទីរជំនាញរាជធានី ខេត្ត | 30.462,2 |

| តារាង ៩៖ គម្រោងចំណាយថវិការបស់ក្រសួងកិច្ចការនារី តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ ២០២៦ |
|---|---|
| **សរុបរួម** | **52.067,0** |
| **កម្មវិធីទី១៖ កែប្រែស្ថានភាពសេដ្ឋកិច្ច សង្គមរបស់ស្ត្រី** | **10.876,1** |
| អនុកម្មវិធីទី១៖ លើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ | 236,0 |
| អនុកម្មវិធីទី២៖ លើកកម្ពស់ការអប់រំ និងសុខុមាលភាពសង្គម | 218,6 |
| អនុកម្មវិធីទី៣៖ អភិវឌ្ឍន៍សេដ្ឋកិច្ចស្ត្រី និងគ្រួសារ | 4.347,9 |
| អនុកម្មវិធីទី៤៖ ការលើកកម្ពស់សុខភាពរបស់ស្ត្រី និងកុមារ | 1.449,2 |

| តារាង ៩៖ គម្រោងចំណាយចរិការបស់ក្រសួងកិច្ចការនារី<br>តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ ២០២៦ |
|---|---|
| អនុកម្មវិធីទី៥៖ កែប្រែស្ថានភាពសេដ្ឋកិច្ច សង្គមរបស់ស្ត្រី ថ្នាក់រាជធានី-ខេត្ត | 4.624,4 |
| **កម្មវិធីទី២៖ កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី** | **3.103,0** |
| អនុកម្មវិធីទី១៖ ទប់ស្កាត់ការរំលោភបំពានលើស្ត្រី | 16,8 |
| អនុកម្មវិធីទី២៖ ពង្រឹងសមត្ថភាពមន្ត្រី/ភ្នាក់ងារនគរបាលយុត្តិធម៌ | 128,2 |
| អនុកម្មវិធីទី៣៖ ទប់ស្កាត់គ្រឿងញៀន និងអំពើជួញដូរមនុស្ស | 106,9 |
| អនុកម្មវិធីទី៤៖ ទប់ស្កាត់អំពើហិង្សាលើស្ត្រី | 233,8 |
| អនុកម្មវិធីទី៥៖ លើកកម្ពស់កិច្ចការពារស្ត្រីពិការ | 754,9 |
| អនុកម្មវិធីទី៦៖ កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី ថ្នាក់រាជធានី-ខេត្ត | 1.862,4 |
| **កម្មវិធីទី៣៖ ការបញ្ជ្រាបយេនឌ័រ ក្នុងគោលនយោបាយជាតិ និងតាមវិស័យ** | **6.265,4** |
| អនុកម្មវិធីទី១៖ អភិវឌ្ឍសមត្ថភាពស្តីពី ការបញ្ជ្រាបយេនឌ័រ | 112,2 |
| អនុកម្មវិធីទី២៖ ផ្សព្វផ្សាយកម្មវិធីនារីរតនៈ | 836,5 |
| អនុកម្មវិធីទី៣៖ ការអនុវត្តអនុសញ្ញាអន្តរជាតិស្តីពី ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី (CEDAW) | 967,3 |
| អនុកម្មវិធីទី៤៖ ស្ត្រី និងការធ្វើសេចក្តីសម្រេច | 248,4 |
| អនុកម្មវិធីទី៥៖ ការបញ្ជ្រាបយេនឌ័រក្នុងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ | 1.813,8 |
| អនុកម្មវិធីទី៦៖ លើកកម្ពស់សមភាពយេនឌ័រ ថ្នាក់រាជធានី-ខេត្ត | 2.287,2 |
| **កម្មវិធីទី៤៖ ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ** | **31.822,5** |
| អនុកម្មវិធីទី១៖ ការរៀបចំផែនការស្ថិតិ និងការត្រួតពិនិត្យវាយតម្លៃឆ្លើយតបនឹងយេនឌ័រ | 256,3 |
| អនុកម្មវិធីទី២៖ ពង្រឹងការងារហិរញ្ញវត្ថុសវនកម្មផ្ទៃក្នុង និងអធិការកិច្ច | 119,9 |
| អនុកម្មវិធីទី៣៖ កិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីសមភាពយេនឌ័រ | 98,9 |
| អនុកម្មវិធីទី៤៖ អភិវឌ្ឍន៍សមត្ថភាពលើការងារគ្រប់គ្រងរដ្ឋបាល | 280,0 |
| អនុកម្មវិធីទី៥៖ សេវាគាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈ | 9.851,4 |
| អនុកម្មវិធីទី៦៖ សេវាគាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈ ថ្នាក់រាជធានី-ខេត្ត | 21.216,0 |

| តារាង ១០៖ គម្រោងចំណាយចរិការបស់ក្រសួងធម្មការ និងសាសនា<br>តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ ២០២៦ |
|---|---|
| **សរុបរួម** | **77.359,5** |
| **កម្មវិធីទី ១ ៖  ការរក្សាសុខដុមនីយកម្មសាសនា** | **9.125,8** |
| អនុកម្មវិធីទី ១ ៖ ការបង្កើនកិច្ចអភិរក្សបេតិកភណ្ឌវប្បធម៌រូបី | 4.361,0 |
| អនុកម្មវិធីទី ២ ៖ ការលើកតម្កើងតម្លៃបេតិកភណ្ឌវប្បធម៌រូបី | 208,4 |
| អនុកម្មវិធីទី ៣៖ កិច្ចគាំពារនិងលើកតម្កើងតម្លៃបេតិកភណ្ឌវប្បធម៌ តំបន់រមណីយដ្ឋានអង្គរ | 305,4 |
| អនុកម្មវិធីទី ៤ ៖ កិច្ចគាំពារនិងលើកតម្កើងតម្លៃបេតិកភណ្ឌវប្បធម៌តំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ និងប្រាសាទកោះកេរ | 4.251,0 |
| **កម្មវិធីទី២ ៖ ការលើកស្ទួយបេតិកភណ្ឌវប្បធម៌អរូបី** | **36.116,1** |

| តារាង ១០៖ គម្រោងចំណាយថវិការបស់ក្រសួងធម្មការ និងសាសនា តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ ២០២៦ |
|---|---|
| អនុកម្មវិធីទី ១ ៖ ការពង្រឹងកិច្ចអភិរក្សបេតិកភណ្ឌវប្បធម៌អរូបី | 2.034,7 |
| អនុកម្មវិធីទី ២ ៖ ការលើកតម្លៃបេតិកភណ្ឌវប្បធម៌អរូបី | 13.423,7 |
| អនុកម្មវិធីទី ៣ ៖ សេវាគាំទ្រការលើកស្ទួយបេតិកភណ្ឌវប្បធម៌អរូបី ថ្នាក់រាជធានី ខេត្ត | 20.657,7 |
| **កម្មវិធីទី ៣ ៖ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ** | **32.117,6** |
| អនុកម្មវិធីទី ១ ៖ ការពង្រឹងសមត្ថភាពនិងប្រសិទ្ធភាពការងាររបស់អង្គភាព | 12.458,9 |
| អនុកម្មវិធីទី ២ ៖ ការបណ្ដុះបណ្ដាលធនធានមនុស្សលើវិស័យវប្បធម៌កម្រិតមធ្យម | 297,4 |
| អនុកម្មវិធីទី ៣ ៖ ការបណ្ដុះបណ្ដាលធនធានមនុស្សលើវិស័យវប្បធម៌ កម្រិតឧត្ដម | 113,3 |
| អនុកម្មវិធីទី ៤ ៖ ការពង្រឹងយន្តការការងាររបស់គណៈកម្មាធិការជាតិបេតិកភណ្ឌពិភពលោក | 19.248,0 |

| តារាង ១១៖ គម្រោងចំណាយថវិការបស់ក្រសួងទេសចរណ៍ តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ ២០២៦ |
|---|---|
| **សរុបរួម** | **95.937,0** |
| **កម្មវិធីទី១៖ ការគ្រប់គ្រង និងពង្រឹងគុណភាពឧស្សាហកម្មទេសចរណ៍** | **13.776,2** |
| អនុកម្មវិធីទី១៖ គ្រប់គ្រងគុណភាពឧស្សាហកម្មទេសចរណ៍ និងសេវាកម្មទេសចរណ៍ "សេវាមួយស្តង់ជាមួយ" | 6.209,1 |
| អនុកម្មវិធីទី២៖ ការគ្រប់គ្រង និងពង្រឹងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ | 980,0 |
| អនុកម្មវិធីទី៣៖ ការពង្រឹងចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋាន សេវាល្អ បដិសណ្ឋារកិច្ចល្អ" | 873,1 |
| អនុកម្មវិធីទី៤៖ ទ្រទ្រង់ដំណើរការសាលាវិជ្ជាជីវៈទេសចរណ៍ | 50,0 |
| អនុកម្មវិធីទី៥៖ បង្កើនការគ្រប់គ្រងឧស្សាហកម្មទេសចរណ៍និងការប្រឡងប្រណាំងនៅរាជធានី-ខេត្ត | 5.664,0 |
| **កម្មវិធីទី២៖ ការអភិវឌ្ឍទេសចរណ៍ និងសហប្រតិបត្តិការអន្តរជាតិ** | **22.041,3** |
| អនុកម្មវិធីទី១៖ ការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការទេសចរណ៍ | 2.118,9 |
| អនុកម្មវិធីទី២៖ ការផ្សព្វផ្សាយទេសចរណ៍កម្ពុជាទៅកាន់ទីផ្សារក្នុងស្រុក និងក្រៅប្រទេស | 6.928,2 |
| អនុកម្មវិធីទី៣៖ ការរៀបចំផែនការ ការវិនិយោគ ការអភិវឌ្ឍផលិតផលទេសចរណ៍ សហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ | 7.140,2 |
| អនុកម្មវិធីទី៤៖ ការបង្កើនប្រសិទ្ធភាពនៃការផ្សព្វផ្សាយទេសចរណ៍កម្ពុជា និងកិត្តិនាមកម្ពុជា និងភាពជាដៃគូជាមួយផ្នែកឯកជន | 2.000,0 |
| អនុកម្មវិធីទី៥៖ ផែនការ អភិវឌ្ឍន៍ផលិតផល និងវិនិយោគទេសចរណ៍ រាជធានី-ខេត្ត | 3.854,0 |
| **កម្មវិធីទី៣៖ ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ** | **60.119,5** |
| អនុកម្មវិធីទី១៖ បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងការងាររដ្ឋបាលរបស់ស្ថាប័ន និងសម្រួលការធ្វើដំណើរ និងសុវត្ថិភាពរបស់ភ្ញៀវទេសចរ | 646,5 |
| អនុកម្មវិធីទី២៖ គ្រប់គ្រង និងអភិវឌ្ឍន៍សមត្ថភាពមន្ត្រីរាជការ | 13.622,0 |

| តារាង ១១៖ គម្រោងចំណាយចរិការបស់ក្រសួងទេសចរណ៍ តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ ២០២៦ |
|---|---|
| អនុកម្មវិធីទី៣៖ ការគ្រប់គ្រងគណនេយ្យ និងហិរញ្ញវត្ថុ | 5.736,7 |
| អនុកម្មវិធីទី៤៖ ការងារនីតិកម្ម សវនកម្មផ្ទៃក្នុង និងអធិការកិច្ច | 959,5 |
| អនុកម្មវិធីទី៥៖ ការគ្រប់គ្រងស្ថិតិ សិក្សាស្រាវជ្រាវរៀបចំគោលនយោបាយ លើកកម្ពស់សមត្ថភាពមន្ត្រីរាជការ និងឌីជីថលនីយកម្មទេសចរណ៍ | 994,4 |
| អនុកម្មវិធីទី៦៖ កិច្ចការសម្របសម្រួលអន្តរវិស័យ | 449,4 |
| អនុកម្មវិធីទី៧៖ ការគ្រប់គ្រងការប្រមូលចំណូលពីរមណីយដ្ឋានអង្គរ ប្រាសាទកោះកែរ និងកំពង់ផែទេសចរណ៍ចុងឃ្នៀស | 19.268,0 |
| អនុកម្មវិធីទី៨៖ កិច្ចការគាំទ្រទេសចរណ៍ រាជធានី-ខេត្ត | 18.443,0 |

| តារាង ១២៖ គម្រោងចំណាយចរិការបស់ក្រសួងធនធានទឹក និងឧតុនិយម តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ ២០២៦ |
|---|---|
| **សរុបរួម** | **311.855,0** |
| **កម្មវិធីទី១៖ ការគ្រប់គ្រង និងការអភិវឌ្ឍវិស័យធនធានទឹក** | **253.276,6** |
| អនុកម្មវិធីទី១៖ កិច្ចដំណើរការ និងការជួសជុលថែទាំប្រព័ន្ធធារាសាស្ត្រ (ន.ធារាសាស្ត្រកសិកម្ម) | 95.353,7 |
| អនុកម្មវិធីទី២៖ ការស្តារ ជួសជុល និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ (ន.វិស្វកម្ម) | 128.058,2 |
| អនុកម្មវិធីទី៣៖ ការបង្កើត និងការគ្រប់គ្រងសហគមន៍កសិករប្រើប្រាស់ទឹកប្រកបដោយនិរន្តរភាព (ន.សហគមន៍កសិករប្រើប្រាស់ទឹក) | 6.080,7 |
| អនុកម្មវិធីទី៤៖ ការជំរុញអនុវត្តផែនការយុទ្ធសាស្ត្ររបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា (គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា) | 660,0 |
| អនុកម្មវិធីទី៥៖ ការងារសម្របសម្រួល និងការពង្រឹងកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូ (គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា) | 800,0 |
| អនុកម្មវិធីទី៦៖ ការពង្រឹងស្ថាប័ន និងធនធានមនុស្ស (គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា) | 8.383,0 |
| អនុកម្មវិធីទី៧៖ សេវាគាំទ្រកិច្ចដំណើរការ ការជួសជុល និងថែទាំ ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្ររបស់មន្ទីរជំនាញរាជធានី-ខេត្ត | 13.941,0 |
| **កម្មវិធីទី២៖ ការគ្រប់គ្រង និងកាត់បន្ថយទឹកជំនន់ គ្រោះរាំងស្ងួត និងទឹកប្រៃ** | **5.327,0** |
| អនុកម្មវិធីទី១៖ ការងារអន្តរាគមន៍បូមទឹកសង្គ្រោះស្រូវ និងទប់ទល់គ្រោះធម្មជាតិ (ន.ធារាសាស្ត្រកសិកម្ម) | 1.679,5 |
| អនុកម្មវិធីទី២៖ ការសាងសង់ ជួសជុល និងថែទាំម៉ាស៊ីនបូមទឹកចល័ត និងស្ថានីយបូមទឹក (ន.ធារាសាស្ត្រកសិកម្ម) | 1.136,5 |
| អនុកម្មវិធីទី៣៖ ការគ្រប់គ្រងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត របស់មន្ទីរជំនាញរាជធានី-ខេត្ត | 2.511,0 |
| **កម្មវិធីទី៣៖ ការការពារ និងការអភិរក្សវិស័យធនធានទឹក** | **6.867,2** |

| តារាង ១២៖ គម្រោងចំណាយថវិការបស់ក្រសួងធនធានទឹក និងឧតុនិយម តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ ២០២៦ |
|---|---|
| អនុកម្មវិធីទី១៖ ការគ្រប់គ្រងធនធានទឹកចំរុះ និងអាងទន្លេប្រកបដោយនិរន្តរភាព (ន.គ្រប់គ្រង និងអភិរក្សធនធានទឹក) | 670,2 |
| អនុកម្មវិធីទី២៖ ការការពារ ថែរក្សា គ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងប្រព័ន្ធអេកូឡូស៊ីនៅតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ (អាជ្ញាធរទន្លេសាប) | 2.200,0 |
| អនុកម្មវិធីទី៣៖ ការគ្រប់គ្រងកិច្ចការរដ្ឋបាលទូទៅ បុគ្គលិក ប្រព័ន្ធព័ត៌មានវិទ្យា និងកិច្ចសហប្រតិបត្តិការជាមួយដៃគូពាក់ព័ន្ធ (អាជ្ញាធរទន្លេសាប) | 3.997,0 |
| **កម្មវិធីទី៤៖ ពង្រឹងការគ្រប់គ្រង នវានុវត្តន៍លើព័ត៌មាន និងទិន្នន័យធនធានទឹក និងឧតុនិយម** | **8.359,8** |
| អនុកម្មវិធីទី១៖ ការរៀបចំចងក្រងបញ្ជីសារពើភណ្ឌ និងគ្រប់គ្រងប្រព័ន្ធទិន្នន័យស្ថិតិរបស់ក្រសួងសម្រាប់លើកផែនការអភិវឌ្ឍលើវិស័យធនធានទឹក និងឧតុនិយម រយៈពេលខ្លី មធ្យម និងវែងលើគ្រប់ផ្នែកទាំងអស់ (ន.ផែនការ និងសហប្រតិបត្តិការអន្តរជាតិ) | 523,2 |
| អនុកម្មវិធីទី២៖ ការគ្រប់គ្រងប្រព័ន្ធទិន្នន័យជលសាស្ត្រ ការគ្រប់គ្រងច្រាំងទន្លេ និងការត្រួតពិនិត្យគុណភាពទឹក (ន.ជលសាស្ត្រ និងការងារទន្លេ) | 862,8 |
| អនុកម្មវិធីទី៣៖ ការគ្រប់គ្រងព័ត៌មានឧតុនិយមប្រកបដោយប្រសិទ្ធភាព (ន.ឧតុនិយម) | 1.785,6 |
| អនុកម្មវិធីទី៤៖ ការគ្រប់គ្រងធនធានទឹកក្រោមដី និងការសិក្សាស្រាវជ្រាវចងក្រងទិន្នន័យទឹកក្រោមដី (ន.ទឹកស្អាត និងអនាម័យ) | 3.675,2 |
| អនុកម្មវិធីទី៥៖ ការគាំទ្រសេវាការគ្រប់គ្រងប្រព័ន្ធទិន្នន័យឧតុនិយម និងជលសាស្ត្ររបស់មន្ទីរជំនាញរាជធានី-ខេត្ត | 1.513,0 |
| **កម្មវិធីទី៥៖ ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ** | **38.024,4** |
| អនុកម្មវិធីទី១៖ ការកែលម្អការគ្រប់គ្រងរដ្ឋបាល និងការកសាងអភិវឌ្ឍន៍សមត្ថភាពមន្ត្រី (ន.រដ្ឋបាល និងធនធានមនុស្ស) | 528,9 |
| អនុកម្មវិធីទី២៖ ការរៀបចំផែនការគោលនយោបាយយុទ្ធសាស្ត្រ និងអភិវឌ្ឍន៍វិស័យធនធានទឹក និងឧតុនិយម (ន.ផែនការ និងសហប្រតិបត្តិកាអន្តរជាតិ) | 433,0 |
| អនុកម្មវិធីទី៣៖ ការបង្កើនប្រសិទ្ធភាពការគ្រប់គ្រង និងការអនុវត្តថវិកា (ន.ហិរញ្ញវត្ថុ) | 11.184,1 |
| អនុកម្មវិធីទី៤៖ ការអភិវឌ្ឍធនធានមនុស្សលើវិស័យធនធានទឹក (មជ្ឈមណ្ឌលសេវាបច្ចេកទេសប្រព័ន្ធធារាសាស្ត្រ ឧតុនិយម) | 305,2 |
| អនុកម្មវិធីទី៥៖ ការធ្វើឱ្យប្រសើរឡើងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងរបស់សវនដ្ឋាន (ន.សវនកម្មផ្ទៃក្នុង) | 151,2 |
| អនុកម្មវិធីទី៦៖ សេវាគាំទ្ររដ្ឋបាល ហិរញ្ញវត្ថុ និងការកសាងសមត្ថភាពរបស់មន្ទីរជំនាញរាជធានី-ខេត្ត | 25.422,0 |

| តារាង ១៣៖ គម្រោងចំណាយថវិការបស់ក្រសួងពាណិជ្ជកម្ម តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ ២០២៦ |
|---|---|
| **សរុបរួម** | **138.645,0** |
| **កម្មវិធីទី១៖ ការលើកកម្ពស់ការផ្តល់សេវាសាធារណៈ អភិវឌ្ឍន៍កម្មសិទ្ធិបញ្ញា និងវិស័យឯកជន** | **27.267,0** |

| តារាង ១៣៖ គម្រោងចំណាយថវិការបស់ក្រសួងពាណិជ្ជកម្ម តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ ២០២៦ |
|---|---|
| អនុកម្មវិធីទី១៖ ការគ្រប់គ្រង និងលើកកម្ពស់ការផ្តល់សេវាសាធារណៈ | 9.941,3 |
| អនុកម្មវិធីទី២៖ ការជំរុញពាណិជ្ជកម្ម និងពិពិធកម្មទីផ្សារ | 6.415,6 |
| អនុកម្មវិធីទី៣៖ ការជំរុញនិងអភិវឌ្ឍន៍វិស័យឯកជន កិច្ចការនីតិកម្ម អភិវឌ្ឍន៍ប្រព័ន្ធព័ត៌មានវិទ្យានិងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ | 3.155,1 |
| អនុកម្មវិធីទី៤៖ ការផ្តល់សេវាសាធារណៈ ការជំរុញពាណិជ្ជកម្ម និងការអភិវឌ្ឍផ្នែកឯកជននៅកម្រិតមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត | 7.755,0 |
| **កម្មវិធីទី២៖ ការការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងអនុលោមភាពនៃផលិតផលទំនិញនិងសេវា** | **24.649,0** |
| អនុកម្មវិធីទី១៖ ការត្រួតពិនិត្យផលិតផលទំនិញនិងសេវា និងការឃ្លាំពិនិត្យទីផ្សារ | 3.845,7 |
| អនុកម្មវិធីទី២៖ ការអភិវឌ្ឍសមត្ថភាព និងការពង្រឹងប្រព័ន្ធគ្រប់គ្រងមន្ទីរពិសោធន៍ | 20.444,3 |
| អនុកម្មវិធីទី៣៖ ការអភិវឌ្ឍ និងការពង្រឹងហេដ្ឋារចនាសម្ព័ន្ធកិច្ចការហោឡាល | 359,0 |
| **កម្មវិធីទី៣៖ ការពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្មអន្តរជាតិ** | **9.475,0** |
| អនុកម្មវិធីទី១៖ ការជំរុញកិច្ចសហប្រតិបត្តិការនិងសមាហរណកម្មសេដ្ឋកិច្ច ពាណិជ្ជកម្មក្នុងក្របខ័ណ្ឌទ្វេភាគី អនុតំបន់ តំបន់ និងពិភពលោក | 6.496,9 |
| អនុកម្មវិធីទី២៖ ការជំរុញកិច្ចសហប្រតិបត្តិការនិងសមាហរណកម្មសេដ្ឋកិច្ច ពាណិជ្ជកម្មក្នុងក្របខ័ណ្ឌ WTO និងគ្រប់គ្រងជំនួយពាណិជ្ជកម្ម | 2.978,1 |
| **កម្មវិធីទី៤៖ ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ** | **77.254,0** |
| អនុកម្មវិធីទី១៖ ការពង្រឹងស្ថាប័ននិងធនធានមនុស្ស ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងយេនឌ័រ | 60.187,8 |
| អនុកម្មវិធីទី២៖ ការពង្រឹងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង | 79,2 |
| អនុកម្មវិធីទី៣៖ សេវាគាំទ្ររដ្ឋបាល ហិរញ្ញវត្ថុ និងកសាងសមត្ថភាពនៅកម្រិតមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត | 16.987,0 |

| តារាង ១៤៖ គម្រោងចំណាយថវិការបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ ២០២៦ |
|---|---|
| **សរុបរួម** | **329.956,0** |
| **កម្មវិធីទី១៖ ការអភិវឌ្ឍខ្សែច្រវាក់ផលិតកម្មកសិកម្ម** | **85.804,9** |
| អនុកម្មវិធីទី១៖ ការអភិវឌ្ឍខ្សែច្រវាក់ផលិតកម្មដំណាំ | 30.257,6 |
| អនុកម្មវិធីទី២៖ ការអភិវឌ្ឍខ្សែច្រវាក់តម្លៃសត្វ | 16.226,6 |
| អនុកម្មវិធីទី៣៖ ការអភិវឌ្ឍខ្សែច្រវាក់តម្លៃជលផល | 2.648,1 |
| អនុកម្មវិធីទី៤៖ ការអភិវឌ្ឍធនធានព្រៃឈើ | 4.519,4 |

| តារាង ១៤៖ គម្រោងចំណាយថវិការបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>តាមកម្មវិធី-អនុកម្មវិធី | ច្បាប់ ២០២៦ |
|---|---|
| អនុកម្មវិធីទី៥៖ ការអភិវឌ្ឍខ្សែច្រវាក់តម្លៃសត្វ និងរុក្ខជាតិកម្រ | 456,2 |
| អនុកម្មវិធីទី៦៖ ការរៀបចំខ្សែច្រវាក់ផលិតកម្មកសិកម្ម រាជធានី-ខេត្ត | 31.697,0 |
| **កម្មវិធីទី២៖ ការគ្រប់គ្រងធនធានធម្មជាតិកសិកម្ម** | **65.185,3** |
| អនុកម្មវិធីទី១៖ ការគ្រប់គ្រង និងអភិវឌ្ឍធនធានព្រៃឈើ និងសត្វព្រៃ | 16.688,2 |
